# مدرسة اهل البيت

# សាលា
# អាស់លុល-បៃត៍

## សៀវភៅ ហ្វីកោ្ហះហ្ុ៍ ថ្នាក់ទី ៤ (អាយុ ៨-៩ ឆ្នាំ)

រ៉ស៊្ហូលុលឡោះហ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ ....................................................................................................៣
មេរៀនទី ២ - អូស្ទ្រូល អុដូខ្ទីន - អារម្ភកថា............................................................. ៦
មេរៀនទី ៣ - តៅហ្វ៊ុដូ ......................................................................................... ៨
មេរៀនទី ៤ - អាុដ្ងាឡាត់ុ.........................................................................................១១
មេរៀនទី ៥ - នូប៉ូវ៉ាត់ុ ..............................................................................................១៤
មេរៀនទី ៦ - អ៊ីម៉ាម៉ាត់ុ ..............................................................................................១៨
មេរៀនទី ៧ - គ្វីយ៉ាម៉ាត់ុ ............................................................................................ ២២
មេរៀនទី ៨ - ហ្ស៊ូរអុុដូខ្ទីន - អារម្ភកថា .................................................................... ២៦
មេរៀនទី ៩ - សាឡើងវិញ - សូត្រក្នុងស្វ៍ឡាត់ុ.............................................................. ២៩
មេរៀនទី ១០ - នៀត ...............................................................................................៣៦
មេរៀនទី ១១ - គ្វីបឡាស់ុ .........................................................................................៣៩
មេរៀនទី ១២ - ពេលវេលាស្វ៍ឡាត់ុ ............................................................................ ៤២
មេរៀនទី ១៣ - តាក់ុគ្វីបាត់ - តាស់បិះហ្វ៍ - ស៊ីយ៉ារ៉ត់ុ ..................................................៤៥
មេរៀនទី ១៤ - អ្វីដែលធ្វើឲ្យខូចវុឌ្ឍុអុំ.......................................................................៥០
មេរៀនទី ១៥ - ទង្វើដែលបណ្តាលឲ្យខូចស្វ៍ឡាត់ុ...................................................... ៥២
មេរៀនទី ១៦ - ត៍ប្ហាប៉ោះត់ុ និង ណាយ៉ាុសាស់ុ..........................................................៥៥
មេរៀនទី ១៧ - ស្មៅម៍ ...............................................................................................៥៩
មេរៀនទី ១៨ - ហ្វ៊ីយ៉ាុប់ (សម្រាប់នារី)................................................................... ៦២

# មេរៀនទី ១

អ៊ីស្លាមមានសេចក្ដីថា ស្ដាប់ឱវាទអល់ឡោះហ្ទាំងស្រុង ។ អល់ឡោះហ្ទ៍បានបង្កើតយើងមក ដូច្នេះព្រះអង្គទ្រង់ញាណអ្វីដែលល្អនិងអាក្រក់សម្រាប់យើង ។ អនុវត្តតាមសាសនាអ៊ីស្លាមយ៉ាងតឹងរ៉ឹង (ដោយចាត់ទុកសាសនាអ៊ីស្លាមជារបៀបរស់នៅ មិនចាត់ទុកត្រឹមតែជាសាសនាទេ) យើងនឹងបានស្ងប់ក្នុងចិត្ត ។ ពាក្យថាអ៊ីស្លាមចេញមកពីពាក្យថាសាឡាម មានន័យថាសេចក្ដីសុខ សេចក្ដីស្ងប់ សន្តិសុខ... ។

អ៊ីស្លាមមិនដូចសាសនាឯទៀតទេ ដែលហៅតាមឈ្មោះរបស់ស្ថាបនជន (អ្នកបង្កើតអ្នកសាង) ឬតាមឈ្មោះរបស់កន្លែងណាមួយដែលសាសនានោះបានកើតឡើង ។ ឧទាហរណ៍៖

១) ឈ្មោះរបស់សាសនាយ៉ាហ្វូឌី ហៅតាមឈ្មោះកុលសម្ព័ន្ធយូដ្ឋាដែលរស់នៅឯតំបន់មួយដែលមានឈ្មោះដូចគ្នា ។

២) សាសនាគ្រិស្ត ហៅតាមឈ្មោះរបស់គ្រិស្ត (ណាប៊ីអ៊ីសាﷺ) ។

សាសនាអ៊ីស្លាម មិនហៅតាមឈ្មោះរបស់ព្រះសាស្ដាមូហាំម៉ាដﷺទេព្រោះយើងមិនជឿថា ព្រះអង្គជាអ្នកបង្កើតសាសនាអ៊ីស្លាមទេ ។ សាសនាអ៊ីស្លាមជាសាសនារបស់អល់ឡោះហ្វ៍ ។

អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងគួរអាន ស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន អាយ៉ាស់ ១៩ ថា៖

*ពិតណាស់ សាសនារបស់អល់ឡោះហ្វ៍គឺសាសនាអ៊ីស្លាម ។ (៣:១៩)*

អល់ឡោះហ្វ៍ ជាពាក្យដែលបណ្ដាមុស្លីមប្រើសម្រាប់ហៅថាព្រះ ។ ប្រសើរបំផុតឲ្យប្រើពាក្យ អល់ឡោះហ្វ៍ ជាជាងពាក្យថា ព្រះ ព្រោះថា៖

ពាក្យថា ព្រះ អាចក្លាយទៅពហុវចនៈរបស់ពាក្យនេះ ពោលគឺ ព្រះច្រើន ។

ពាក្យថា ព្រះ អាចក្លាយទៅឥត្ថីវចនៈ (ភេទស្រី) របស់ពាក្យនេះ ពោលគឺ ទេពធីតា (គឺព្រះស្រី) ។

ពាក្យថា អល់ឡ្ហោះហ្វ៍ មិនមានពហុវចនៈនិងមិនមានឥត្ថីវចនៈទេ ដូច្នេះពាក្យថា អល់ឡ្ហោះហ្វ៍ មានន័យថាព្រះជាម្ចាស់ប្រសើរជាងអស់ពាក្យឯទៀត ។ ពោលគឺ មានព្រះតែមួយគត់ ព្រះអង្គមិនមែនប្រុសហើយក៏មិនមែនស្រីទេដែរ ។

អ៊ីស្លាមជាសាសនាដំបូងបង្អស់ និងចុងក្រោយបង្អស់ដែលព្រះសាស្តាទាំងឡាយ عليهم السلام បានបង្ហាត់បង្រៀនឲ្យដឹង គឺព្រះសាស្តាដែលមានចំនួន ១២៤០០០ អង្គ តាំងពីអាដាំ عليه السلام រហូតមកដល់មូហាំម៉ាដ់ صلى الله عليه وآله وسلم ។
ការអប់រំមូលដ្ឋានរបស់ព្រះសាស្តាទាំងអស់ عليهم السلام ជាការអប់រំមូលដ្ឋានដូចៗគ្នា ទោះបីជូនកាលច្បាប់សាសនាខុសគ្នាក៏ដោយ អាស្រ័យលើសម័យរបស់ព្រះសាស្តានិងអាស្រ័យលើបក្ខភាពនៃប្រជារាស្ត្ររបស់សម័យនោះ
ដែលមានលក្ខណៈគ្រប់គ្រាន់ហើយឬនៅដើម្បី ទទួលការអប់រំរបស់ព្រះសាស្តា ។

ឧទាហរណ៍ បើសិនជាអ្នកចង់អធិប្បាយអំពីរថយន្តឲ្យកុមារយល់ អ្នកប្រាប់គេជាមុនថាវាមានកង់ ហើយវាអាចដឹកគេពីកន្លែងមួយទៅកាន់កន្លែងមួយទៀត ។ ពេលគេធំបន្តិច អ្នកពន្យល់ប្រាប់គេថា រថយន្តមានម៉ាស៊ីនដែលត្រូវការសាំងដើម្បីដំណើរការបាន ។ ពេលគេធំជាងនោះបន្តិច អ្នកអាចពន្យល់ប្រាប់គេជាពិស្តារអំពីដំណើរការរបស់ផ្នែកនីមួយៗរបស់រថយន្ត ដើម្បីនឹងឲ្យគេយល់ជ្រួតជ្រាបឲ្យបានល្អ ។

ដូចគ្នាដែរ ព្រះសាស្តាទាំងអស់ عليهم السلام បានបង្ហាត់បង្រៀនថាមានព្រះតែមួយគត់ ហើយខ្លួនព្រះអង្គជាសាស្តារបស់ព្រះ ។ ក៏ប៉ុន្តែអល់ឡ្ហោះហ្វ៍ដាក់ច្បាប់សាសនាមកដោយថ្លឹងតាមសមត្ថភាពរបស់ប្រជារាស្ត្រ ថាតើគេមានលក្ខណៈគ្រប់គ្រាន់ហើយឬនៅដើម្បីយល់ច្បាប់ទាំងនោះ ។ នៅទីបញ្ចប់ សាសនាអ៊ីស្លាមពេញលេញត្រូវដាក់មកលើពិភពលោកទាំងមូល តាមរយៈព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។

# កិច្ចការសិស្ស ១

ចូរឆ្លើយសំណួរតទៅនេះគឺៈ

១. តើអ៊ីស្លាមមានន័យថាអ្វី ?

______________________________

២.ហេតុអ្វីគេមិនហៅសាសនាអ៊ីស្លាមតាមឈ្មោះរបស់ព្រះសាស្តាមូហាំម៉ាដ្ ﷺ ?

______________________________

៣. ហេតុអ្វីការប្រើពាក្យថា អល់ឡោះហ្វ៍ ប្រសើរជាងការប្រើពាក្យថា ព្រះ ?

______________________________

៤. អ្វីទៅដែលព្រះសាស្តាទាំងអស់តែងតែថា ?

______________________________

ចូរទន្ទេញអាយ៉ាស់ ១៩ ស៊ូរ៉ោះត៍ អាលី អុីមរ៉ន ខាងក្រោមនេះ ឲ្យចាំស្ទាត់គឺៈ



**មេរៀនទី ២**

# អ៊ូស៊្វូល អ៊ុដ្ឌីន - អារម្ភកថា

សាសនាអ៊ីស្លាមប្រៀបបាននឹងដើមឈើដែលដុះឫសនិងបែកមែក ។

គ្រឹះ (ឬ ឫសកែវ) របស់សាសនាហៅថា អ៊ូស៊្វូល អ៊ុដ្ឌីន (أصول الدين) ។
មែក ឬ សាខារបស់សាសនាហៅថា ហ្វ៊ូរូអ៊ុដ្ឌីន (فروع الدين) ។
ដូចដើមឈើដែរ ឫសសំខាន់ជាងមែក ក្នុងសាសនាអ៊ីស្លាម អ៊ូស៊្វូល សំខាន់បំផុតសម្រាប់ជំនឿជាង ហ្វ៊ូរូអ៊ុ ទៅទៀត ។
បើគេកាត់មែកឈើ ដើមឈើនៅតែរស់ មែកវានឹងដុះឡើងវិញបន្តិចម្តងៗ តែបើគេកាត់ឫសវា ដើមឈើនឹងស្លាប់ ។
ដូចគ្នាដែរ បើគេមិនយល់ ហ្វ៊ូរូអ៊ុ (គឺមែក) យ៉ាងជ្រាលជ្រៅទេ គេនៅតែអាចអនុវត្តតាមហ្វ៊ូរូអ៊ុទាំងនោះបាន សាសនានឹងនៅតែមានជាដរាប គេនឹងយល់ន័យម្តងបន្តិចៗ ។
តែបើគេមិនយល់អ៊ូស៊្វូល (គ្រឹះ ឬ ឫសវែក) ទេ ជំនឿរបស់គេនឹងស្លាប់ព្រោះវាជាជំនឿមូលដ្ឋានរបស់សាសនាអ៊ីស្លាម ។
មុស្លិមរាល់គ្នាចាំបាច់ត្រូវយល់ អ៊ូស៊្វូល ឲ្យបានល្អបំផុត តាមសមត្ថភាពរបស់ខ្លួន ។
ក្នុង អ៊ូស៊្វូល ពុំមានតាក់លីដ្ (تقليد ការធ្វើត្រាប់តាម) ទេ តែក្នុង ហ្វ៊ូរូអ៊ុ ត្រូវមានតាក់លីដ្ជាចាំបាច់ ។

អ៊ូស៊្វូល អ៊ុដ្ឌីន (ឫសកែវ ឬ គ្រឹះរបស់សាសនា) មាន ៥ ប្រការគឺៈ

១.តៅហ៊ីដ្ (تَوْحيد) : មានតែអល់ឡោះហ្វ៍មួយគត់ ។
២.អាដ្ឌាឡាត់ (عدالة) : អល់ឡោះហ្វ៍យុត្តិធម៌ ។
៣.នូប៊ូវាត់ (نبوة) : អល់ឡោះហ្វ៍បានចាត់បញ្ជូនមកនូវ ១២៤ ០០០ ព្រះសាស្តាដើម្បីដឹកនាំយើង ។
៤.អ៊ីម៉ាម៉ាត់ (إمامة) : អល់ឡោះហ្វ៍បានចាត់បញ្ជូនមកនូវ ១២ អ៊ីមុាំដើម្បីដឹកនាំយើង ។
៥.គ្វីយ៉ាម៉ាត់ (القيامة) : ថ្ងៃជំនុំជម្រះនឹងកើតមានឡើង ។

# កិច្ចការសិស្ស ២

ចូរគូរដើមឈើនៅពេលដែលមានអ្វីកើតឡើងចំពោះវា ប្រសិនបើ ៖

១) គេកាត់មែកវា ដូចដែលបង្ហាញនៅលើរូបខាងក្រោមនេះ ។



២) គេកាត់ឫសវា ដូចដែលបង្ហាញនៅលើរូបខាងក្រោមនេះ ។



**មេរៀនទី ៣**

# តៅហ៊ីដ្វ

តៅហ៊ីដ្វមានន័យថា មានតែអល់ឡោះហ្វ៍មួយគត់ ។

អល់ឡោះហ្វ៍ពន្យល់តៅហ៊ីដ្វនៅក្នុងព្រះគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៍ អ៊ីខ្លាស្វ៍ គឺ ៖

| | |
|---|---|
| ដោយព្រះនាមអល់ឡោះហ្វ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។ | بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ |
| ចូរអ្នកថ្លែងថា៖ "ព្រះអង្គគឺអល់ឡោះហ្វ៍ ព្រះមួយគត់ | قُلۡ هُوَ ٱللَّهُ أَحَدٌ |
| អល់ឡោះហ្វ៍មិនត្រូវការអ្វីឡើយ តែសព្វសារពើត្រូវការព្រះអង្គ | ٱللَّهُ ٱلصَّمَدُ |
| ព្រះអង្គមិនឲ្យកំណើតទេ ព្រះអង្គមិនត្រូវប្រសូតមកទេ | لَمۡ يَلِدۡ وَلَمۡ يُولَدۡ |
| ពុំមានអ្វីដូចព្រះអង្គឡើយ ។" | وَلَمۡ يَكُن لَّهُۥ كُفُوًا أَحَدُۢ |

ប្រសើរបំផុតគឺប្រើពាក្យថា "អល់ឡោះហ្វ៍" ជាជាងពាក្យថា "ព្រះ" ពីព្រោះ ៖
"ព្រះ" អាចក្លាយជាពហុវចនៈរបស់ពាក្យថា "ព្រះ" នេះ ពោលគឺ ព្រះច្រើន ។
"ព្រះ" អាចក្លាយជាឥត្ថីវចនៈរបស់ពាក្យថា "ព្រះ" នេះ ពោលគឺ ទេពធីតា ។
ពាក្យថា "អល់ឡោះហ្វ៍" មិនមានពហុវចនៈនិងមិនមានឥត្ថីវចនៈទេ ហើយនេះជាវិធីប្រសើរបំផុតសម្រាប់ហៅអល់ឡោះហ្វ៍ ។ មានតែព្រះមួយគត់ ព្រះអង្គមិនមែនប្រុស ហើយក៏មិនមែនស្រីទេដែរ ។

ជឿតៅហ៊ីដ្វមានន័យថា អ្នកមិនត្រឹមតែជឿតែព្រះមួយប៉ុណ្ណោះទេ អ្នកថែមទាំងពឹងផ្អែកលើព្រះអង្គក្នុងរឿងអ្វីៗទាំងអស់ហើយអ្នកធ្វើអ្វីគ្រប់យ៉ាងដើម្បីព្រះអង្គ ។

បើអ្នកពឹងផ្អែកលើអល់ឡោះហ្វ៍ទាំងស្រុងពិតមែន ទោះបីក្នុងរឿងអ្វីក៏ដោយ អ្នកនឹង

មិនត្រូវការអ្នកណាឡើយ ហើយអ្នកនឹងមិនខ្លាចអ្នកណាឡើយ ។

បើអ្នកធ្វើអ្វីដើម្បីអល់ឡោះហ្ទ៍មែន អ្នកច្បាស់ជានឹងយល់ថាអ្វីគឺអ៊ីស្លាម (ជារបៀបរស់នៅ មិនមែនត្រឹមតែជាសាសនាធម្មតាប៉ុណ្ណោះទេ) ។ អ្នកនឹងហូប នឹងផឹក នឹងដេក នឹងសិក្សា នឹងស្តាប់បង្គាប់ ឬនឹងស្រឡាញ់អ្នកដទៃដើម្បីអល់ឡោះហ្ទ៍មួយគត់ ។

ថ្ងៃមួយ ប៊ីប៊ី ស្វៃណាប់سلام الله عليهاបានសួរអ៊ីម៉ាំអាលីصلوات الله عليه والسلام ព្រះបិតាព្រះនាង ថាតើព្រះអង្គصلوات الله عليه والسلامអាចស្រឡាញ់របស់ពីរបានដូចម្តេចទៅ អល់ឡោះហ្ទ៍និងខ្លួនព្រះនាងផ្ទាល់ដែលជាបុត្រីរបស់ព្រះអង្គصلوات الله عليه والسلام ។ ព្រះអង្គصلوات الله عليه والسلامបានឆ្លើយសំណួរនេះថា ព្រះអង្គصلوات الله عليه والسلامមានតែសេចក្តីស្រឡាញ់មួយប៉ុណ្ណោះ គឺសេចក្តីស្រឡាញ់អល់ឡោះហ្ទ៍ ។ សេចក្តីស្រឡាញ់របស់ព្រះអង្គصلوات الله عليه والسلامចំពោះបុត្រីព្រះអង្គصلوات الله عليه والسلامនោះ គឺដោយសារតែអល់ឡោះហ្ទ៍បានផ្តាំឲ្យព្រះអង្គصلوات الله عليه والسلامស្រឡាញ់បុត្រីរបស់ព្រះអង្គصلوات الله عليه والسلام ។

អល់ឡោះហ្ទ៍មានព្រះបន្ទូលថា ព្រះអង្គមិនចង់បានទេ បើអ្នកធ្វើអ្វីមួយដើម្បីអ្នកដទៃនោះ ។ បើអ្នកចង់ដឹងថាអ្នកធ្វើអ្វីមួយដើម្បីអល់ឡោះហ្ទ៍មែន ចូរអ្នកសង្កេតមើលថាតើអ្នកធ្វើស្វ៍ឡាត្ទ៍នៅផ្ទះតែម្នាក់ឯង ដូចពេលដែលអ្នកធ្វើស្វ៍ឡាត្ទ៍នៅឯម៉ាស់ញ៉ិដ្ទ៍ដែរ ឬទេ ពេលដែលអ្នកផងមើលមកអ្នក ។

# កិច្ចការសិស្ស ៣

ចូរសរសេរន័យរបស់ស៊ូរ៉ោះត៍ អាល់-អ៊ីខ្លាស្វ៍ គ្រប់បន្ទាត់នៅខាងក្រោមនេះ និងចូរទន្ទេញឲ្យចាំស្ទាត់ ។




តើអល់ឡោះហ្វ៍បង្ហាត់បង្រៀនយើងឲ្យចេះដឹងអ្វីក្នុងស៊ូរ៉ោះត៍នេះ ?

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

**មេរៀនទី ៤**

# អាុផ្វាឡាត់

អាុផ្វាឡាត់ មានន័យថាអល់ឡោះហ្វយុត្តិធម៌ ។

យុត្តិធម៌របស់អល់ឡោះហ្វមិនមានន័យថា អល់ឡោះហ្វស្មើភាពសម្រាប់មនុស្សទាំងអស់ទេ ។
ស្មើភាពនិងយុត្តិធម៌មិនដូចគ្នាទេ ។
ឧទាហរណ៍ ពេលគ្រូដាក់ពិន្ទុកិច្ចការសិស្សដោយយុត្តិធម៌ សិស្សម្នាក់ៗនឹងទទួលបានពិន្ទុសមតាមទង្វើរបស់ខ្លួន យោលទៅតាមការប្រឹងប្រែង ។ តែបើគ្រូដាក់ពិន្ទុស្មើគ្នា សិស្សគ្រប់រូបនឹងបានទទួលពិន្ទុស្មើគ្នា ដោយមិនគិតទៅលើការខំប្រឹងប្រែង ។
អ្វីដែលអល់ឡោះហ្វធ្វើសុទ្ធតែយុត្តិធម៌ ព្រះអង្គមិនតឹងរ៉ឹង ហើយក៏មិនធ្វើអ្វីដែលលំអៀងពីប្រាជ្ញាញាណទេ ។ យើងអាចមិនយល់ថាហេតុអ្វីអល់ឡោះហ្វធ្វើអ្វីមួយដែលគួរឲ្យតក់ស្លុត តែមិនមានន័យថាព្រះអង្គអយុត្តិធម៌នោះទេ ។
បើសិនជាអ្នកណាមួយអយុត្តិធម៌ ក៏ព្រោះតែ ៖
១) អ្នកនោះអាចមិនដឹងខ្លួនទេថាខ្លួនឯងអយុត្តិធម៌ ។
២) អ្នកនោះចង់បានអ្វីមួយ ដែលខ្លួនមិនអាចយកមកបានដោយមិនប្រព្រឹត្តិដោយអយុត្តិធម៌ ។
៣) អ្នកនោះអាចត្រូវគេបង្ខំឲ្យប្រព្រឹត្តិដោយអយុត្តិធម៌ ។

ករណីទាំងបីខាងលើនេះមិនស័ក្តិសមនឹងអល់ឡោះហ្វទេ ពីព្រោះ ៖
១) ព្រះអង្គប្រកបដោយញាណបារមីដ៏ខ្ពង់ខ្ពស់បំផុត ។
២) ព្រះអង្គមិនត្រូវការអ្វីឡើយ ។
៣) ព្រះអង្គមានព្រះមហិទ្ធិឫទ្ធិលើសលុប ។

បុរសម្នាក់ទៅធ្វើស្វ៍ឡាត់ថ្ងៃសុក្រ ។ តាមផ្លូវ គាត់បានឆ្លៀតចូលទៅសួរកូនស្រីគាត់ទាំងពីរនាក់នៅឯផ្ទះថា តើកូនទាំងពីរចង់ឲ្យគាត់ជួយបួងសួងអល់ឡោះហ្វឲ្យឬទេ

ក្រោយពីស្ទ័ឡាត់រួច ។

កូនម្នាក់បានសូមឲ្យគាត់បួងសួង សូមឲ្យមានភ្លៀងធ្លាក់ព្រោះស្វាមីគាត់ជាកសិករ គាត់ចង់ឲ្យដំណាំរបស់គាត់ឆាប់ដុះ ។

កូនស្រីម្នាក់ទៀតសូមឲ្យគាត់បួងសួង សូមឲ្យបើកថ្ងៃ ដើម្បីនឹងឲ្យផើងដែលស្វាមីគាត់ធ្វើពីដីនោះឆាប់ស្ងួត ។

បុរសជាឪពុកបានទៅកាន់ម៉ាស់ឃ្មិដ្ឋ អារម្មណ៍ច្របូកច្របល់ មិនដឹងនឹងបួងសួងសូមអ្វីទេ ព្រោះកូនស្រីគាត់ម្នាក់ចង់បានថ្ងៃ ឯម្នាក់ទៀតចង់បានភ្លៀង ។

គាត់បានសម្រេចចិត្តថានឹងបួងសួងអល់ឡោះហ្វ៍ សូមឲ្យព្រះអង្គធ្វើអ្វីតាមតែព្រះអង្គទ្រង់យល់ថាយុត្តិធម៌ចុះ ព្រោះនេះជាការដោះស្រាយត្រឹមត្រូវ ។

## កិច្ចការសិស្ស ៤

តើអល់ឡោះហ្វ៍យុត្តិធម៌ ឬ ស្មើភាព តើខុសគ្នាត្រង់ណា ?

________________________________________________
________________________________________________
________________________________________________
______________

**មេរៀនទី ៥**

# នូប៊ូវ៉ាត្ត៎

នូប៊ូវាត្ត៎ (نبوة) គឺជំនឿលើសាស្តា ។

អល់ឡោះហ្វ៍បានចាត់បញ្ជូនមកនូវ ១២៤០០០ ព្រះសាស្តាعليهم السلامដើម្បីដឹកនាំយើង ។ ក្នុងចំណោមសាស្តាទាំង ១២៤០០០ រូបនេះ ព្រះសាស្តាអាដាំﷷជាព្រះសាស្តាដំបូងបង្អស់ ហើយក៏ជាមនុស្សដំបូងបង្អស់ដែរ ។ ព្រះសាស្តាចុងក្រោយបង្អស់ ក្នុងចំណោមព្រះសាស្តាទាំងអស់ នេះគឺព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៉صلى الله عليه وآله وسلم ។

ហេតុអ្វីយើងត្រូវការព្រះសាស្តា ?

បណ្តាព្រះសាស្តាមានបេសកកម្មបង្ហាញយើងនូវមាគ៌ាត្រឹមត្រូវ ព្រះអង្គជាមគ្គុទេសក៏យើង ប្រៀបបាននឹងគ្រូបាធ្យាយ ។ ព្រះអង្គជាមនុស្សដូចយើងដែរ ដូច្នេះយើងអាចយកតម្រាប់តាមព្រះអង្គបាន ព្រះអង្គជាគំរូសម្រាប់យើង ។

បណ្តាព្រះសាស្តាប្រៀបបាននឹងស្ពានរវាងយើងនិងអល់ឡោះហ្វ៍عزّ وجلّ ។

អល់ឡោះហ្វ៍عزّ وجلّមានព្រះបន្ទូលមកកាន់ព្រះសាស្តាដោយមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយបីគឺ ៖

១) ដោយផ្ទាល់ ឧទាហរណ៍ ព្រះសាស្តា មូសាﷷ ។

២) តាមរយៈសុបិន ឧទាហរណ៍ ព្រះសាស្តា អ៊ីបរ៉ហ៊ីមﷷ ។

៣) តាមរយៈទេវតា យ៉ិបរ៉អ៊ីល (جبرائيل) ឧទាហរណ៍ ព្រះសាស្តាមូហ៊ាំម៉ាដ្ឋ៉صلى الله عليه وآله وسلم ។

បន្ទាប់មក ព្រះសាស្តានាំព្រះបន្ទូលអល់ឡោះហ្វ៍عزّ وجلّមកប្រាប់យើង ។

ព្រះសាស្តាមួយចំនួនត្រូវចាត់បញ្ជូនទៅឯបណ្តាកុលសម្ព័ន្ធ ទៅឯបណ្តាសហគមន៍

និងទៅឯបណ្តាគ្រួសារ (ឬត្រកូល) តាមព្រះបញ្ជាអល់ឡោះហ្វ៍ﷻ ។ តែព្រះសាស្តាﷺយើងត្រូវចាត់បញ្ជូនមកកាន់មនុស្សជាតិទាំងអស់ ។

ឋានន្តរស័ក្តិមួយរបស់ព្រះសាស្តាﷺយើង ក្នុងចំណោមឋានន្តរសក្តិឯទៀត គឺ រ៉ោះហ្ម៉ាទុល លិល-អាុឡាមីន មានន័យថា "ពរជ័យសិរីសួស្តីលើភពផែនដែនចក្រវាល" ។ អាស្រ័យហេតុនេះឯងបានជាអល់ឡោះហ្វ៍ﷻមិនធ្វើទណ្ឌកម្មភ្លាមៗអ្នកណាដែលប្រព្រឹត្តល្មើសឥតឈប់ឈរ ដូចកាលពីមុននោះទេ ។

ឧទាហរណ៍ មនុស្សនាសម័យព្រះសាស្តានុះហ្វ៍ﷺត្រូវពន្លង់ទឹក ឯមនុស្សនាសម័យព្រះសាស្តាហ៊្វូដﷺត្រូវកបំផ្លាញចោល ។

ព្រះសាស្តាទាំងឡាយត្រូវមានគុណសម្បត្តិដូចតទៅនេះគឺ ៖
-ត្រូវអល់ឡោះហ្វ៍ﷻជ្រើសរើស ។
-ជាម៉ាក់ស៊ូម (គឺបរិសុទ្ធ) ពោលគឺ មិនមានបាបសោះ ទោះបីបាបដែលបានធ្វើដោយភ្លាំងភ្លាត់ក៏ដោយ ។
-អាចធ្វើឲ្យមានអព្ភូតហេតុបានដោយអល់ឡោះហ្វ៍ﷻអនុញ្ញាត ។
-ជាបុគ្គលដែលសុក្រឹតបំផុតក្នុងសម័យរបស់ខ្លួន (ដោយអាក់ឡាក់ (أخلاق) ពោលគឺ ដោយមានសីលធម៌និងមានការចេះដឹង) ។

ពាក្យអារ៉ាប់សម្រាប់ហៅព្រះសាស្តាគឺ ណាប៊ី ដែលមានពហុវចនៈថា អាន់ប៊ីយ៉ាអ៊ុ (أنبياء) ។ ក្នុងចំណោមអាន់ប៊ីយ៉ាអ៊ុ មួយចំនួនបាននាំមកនូវបញ្ញត្តិថ្មី (ច្បាប់ស្ហារីអាុស៊ុ (شريعة)) ឲ្យប្រជារាស្ត្ររបស់ខ្លួនប្រតិបត្តិតាម គេហៅអាន់ប៊ីយ៉ាអ៊ុទាំងនេះថា រ៉ស៊ូល (رسول ឬ ព្រះសាសនទូត) ។ ដូច្នេះ ឋានន្តរស័ក្តិរ៉ស៊ូលខ្ពស់ជាងឋានន្តរស័ក្តិណាប៊ី ។

មានព្រះសាស្តាប្រាំអង្គដែលមានឋានន្តរស័ក្តិខ្ពស់លើសនោះទៀត គេហៅព្រះសាស្តាទាំងនេះថា អ៊ូលុល-អាុស៊្មុំ (أولوالعزم សាស្តាពិសេស) មាន ៖

- ព្រះសាស្តា នុះហ្វ៍ﷺ ។
- ព្រះសាស្តា អ៊ិបរ៉ហ៊ីមﷺ ។
- ព្រះសាស្តា មូសាﷺ ។

- ព្រះសាស្តា អ៊ីសាﷺ ។
- ព្រះសាស្តា មូហាំម៉ាដ់ﷺ ។

ព្រះសាស្តាបានផ្សាយព្រះរាជសាររបស់អល់ឡោះហ្វ៍ﷻ តាមសមត្ថភាពដែលអាចយល់បានរបស់មនុស្សដែលចម្រើនឡើង ដូច្នេះមនុស្សអាចយល់ជាក់ព្រះរាជសាររបស់អល់ឡោះហ្វ៍ខ្លាំងឡើងៗ ។

ឧទាហរណ៍ ដើម្បីពន្យល់កុមារឲ្យយល់ថាអ្វីគឺរថយន្ត អ្នកនឹងប្រាប់វាថាវាមានកង់ដែលដឹកអ្នកពីកន្លែងមួយទៅកន្លែងមួយទៀត ។ ពេលកុមារធំបន្តិច មានសមត្ថភាពអាចយល់បានច្រើន អ្នកនឹងប្រាប់វាថារថយន្តអាចផ្លាស់កន្លែងបានអាស្រ័យម៉ាស៊ីនដែលប្រើសាំង ។ ពេលកុមារកាន់តែធំឡើងទៀត អ្នកនឹងប្រាប់វាឲ្យដឹងថាម៉ាស៊ីនមានដំណើរការម្តេចខ្លះ ។ល ។

តាមទម្លាប់ ព្រះសាស្តាមាននូវប្រជុំច្បាប់ (ស្ហារីអ៊ុស្ហ) ទុកក្នុងសៀវភៅមួយ ។ គេហៅសៀវភៅទាំងនោះថា ព្រះគម្ពីរ ។

ព្រះសាស្តានុះហ្វ៍ﷺ និងព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺមានព្រះគម្ពីរមួយម្នាក់ តែយើងមិនដឹងក្រៅពីនេះទេអំពីព្រះគម្ពីរទាំងពីរនេះ ។ ព្រះគម្ពីរឯទៀតដែលយើងស្គាល់គឺ ៖

-ព្រះគម្ពីរ តៅរ៉ត (توراة) ត្រូវដាក់ចុះមកឲ្យព្រះសាស្តាមូសាﷺ ។
-ព្រះគម្ពីរ ស្សាប៊ូរ (زبور) ត្រូវដាក់ចុះមកឲ្យព្រះសាស្តាដាវុដﷺ ។
-ព្រះគម្ពីរ អ៊ិនយ៉ីល (إنجيل) ត្រូវដាក់ចុះមកឲ្យព្រះសាស្តាអ៊ីសាﷺ ។
-ព្រះគម្ពីរ គួរអាន (قرءان) ត្រូវដាក់ចុះមកឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺ ។

អ៊ីស្លាមជាសាសនាដំបូងបង្អស់ និងចុងក្រោយបង្អស់ដែលព្រះសាស្តាទាំងអស់បាននាំមកបង្ហាត់បង្រៀន ធ្វើឲ្យសុក្រឹតនិងបង្គ្រប់ពេញលេញដោយព្រះសាស្តាមូហាំម៉ាដ់មុស្តាហ្វាﷺ ។

# កិច្ចការសិស្ស ៥

ចូរប្រាប់ព្រះនាមរបស់ព្រះសាស្ដាអ៊្វលុល-អាុស៊ុំម៍ ?

ចូរឆ្លើយសំណួរតទៅនេះគឺ ៖

១) ចូរប្រាប់គុណសម្បត្តិទាំង ៤ ដែលព្រះសាស្ដាត្រូវមាន ?

___

___

២) តើណាប៊ី និង រ៉សូ៊ល ខុសគ្នាត្រង់ណា ?

___

___

**មេរៀនទី ៦**

# អ៊ីម៉ាម៉ាត្ទ៍

អ៊ីម៉ាម៉ាត្ទ៍ (إمامة) គឺជំនឿលើការចាំបាច់ត្រូវមានមគ្គុទេសក៍ដែលជាអ្នកដឹកនាំក្រោយពីព្រះសាស្តា ﷺ ។ ដូច្នេះ មាន ១២ មគ្គុទេសក៍ (អាអ៊ីម៉ាស្ទ៍ أئمة) ។

អាអ៊ីម៉ាស្ទ៍ ជាពហុវចនៈរបស់ពាក្យថា អ៊ីមុាំ (إمام) ។ អ៊ីមុាំ មានន័យថា មគ្គុទេសក៍ ឬមេដឹកនាំ ។

ដូចព្រះសាស្តាដែរ អាអ៊ីម៉ាស្ទ៍ចាំបាច់ត្រូវមានគុណសម្បត្តិដូចតទៅនេះគឺៈ
-ត្រូវអល់ឡោះហ្វ៍ عزّ وجلّ ជ្រើសរើស ។
-ជាម៉ាក់ស្ទុម (បរិសុទ្ធ ជ្រះថ្លា) ពោលគឺ មិនមានបាបសោះ ទោះបីបាបដែលបានធ្វើដោយភ្លាំងភ្លាត់ក៏ដោយ ។
-អាចធ្វើឲ្យមានអព្ភូតហេតុបានដោយអល់ឡោះហ្វ៍ عزّ وجلّ អនុញ្ញាត ។
-ជាបុគ្គលដែលសុក្រឹតបំផុតក្នុងសម័យកាលរបស់ខ្លួន (ទាំងវិស័យសីលធម៌អាក់ឡាក្ទ៍ ទាំងវិស័យចំណេះចេះដឹង) ។

អាអ៊ីម៉ាស្ទ៍មានចំនួន ១២ រូប គឺៈ

១) អ៊ីមុាំ អ៊ុលី صلوات الله عليه والسلام (علي) ។
២) អ៊ីមុាំ ហ៊ាសាន់ صلوات الله عليه والسلام (الحسن) ។
៣) អ៊ីមុាំ ហ៊ូសែន៍ صلوات الله عليه والسلام (الحسين) ។
៤) អ៊ីមុាំ អ៊ុលី ស៊ែនុល-អ៊ុប៊ីឌីន صلوات الله عليه والسلام (علي زين العابدين) ។
៥) អ៊ីមុាំ មូហាំម៉ាដ្ទ៍ អាល់-បាគៀរ صلوات الله عليه والسلام (محمد الباقر) ។
៦) អ៊ីមុាំ យ៉ាក់ហ្វារ អាស្ទ៍-ស្ទ៍ឌិក្ទ صلوات الله عليه والسلام (جعفر الصادق) ។
៧) អ៊ីមុាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام (موسى الكاظم) ។
៨) អ៊ីមុាំ អ៊ុលី អារ-រីដ្ទ៍ صلوات الله عليه والسلام (علي الرضا) ។

៩) អីមុាំ មូហុាំម៉ាដ់ អាត់-តាគ្ហី صلوات الله عليه والسلام (محمد التقي) ។
១០) អីមុាំ អុាលី អាន់-ណាគ្ហី صلوات الله عليه والسلام (على النقي) ។
១១) អីមុាំ ហុាសាន់ អាល់-អុាស់ការី صلوات الله عليه والسلام (حسن العسكري) ។
១២) អីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌ្ហី صلوات الله عليه والسلام (محمد المهدي) ។

អ៊ីមុាំទី ១២ គឺអ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ហ់ឌ្ហី صلوات الله عليه والسلام ជាអ៊ីមុាំប្រចាំសម័យកាលយើង ព្រះអង្គមានព្រះជន្មនៅឡើយ ។ ដូច្នេះហើយបានជាពេលណាយើងឮព្រះនាមព្រះអង្គ យើងគប្បីងើបឈរ ហើយឱនក្បាលដោយដាក់ដៃស្តាំលើក្បាល ជាកាសម្តែងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ចំពោះព្រះអង្គ ។

ព្រះសាស្តាយើងﷺមានព្រះវចនៈថា មុស្លីមណាស្លាប់ដោយមិនស្គាល់អ៊ីមុាំប្រចាំសម័យកាលរបស់ខ្លួន មុស្លីមរូបនោះនឹងស្លាប់ដូចជនអសទ្ធា ។

ហេតុអ្វីយើងត្រូវការអ៊ីមុាំជាមគ្គុទេសក៍ ទោះបីព្រះសាស្តាﷺបានបង្ហាត់បង្រៀនយើងឲ្យចេះដឹងសាសនាអ៊ីស្លាមសព្វគ្រប់ហើយនោះ ព្រមទាំងបានទុកព្រះមហាគម្ពីរគួរអានឲ្យយើង ?

តួនាទីរបស់អ៊ីមុាំគឺដឹកនាំយើង និងជួយយើងពេលណាយើងមិនយល់អ្វីមួយ និងពេលណាយើងភ្លេចភ្លាំង និងដើម្បីជួយធ្វើអន្តរាគមន៍ឲ្យយើងជាមួយអល់ឡោះហ្វ៍ ។

សម័យថ្ងៃមួយ នៅក្នុងម៉ាស់យ៊ិដ្ឋនាប្រទេសអ៊ីរ៉ាក់ មានបុរសម្នាក់ឈ្មោះ អុាំរ៍ ប៊ិន អុ៊ូបៃដ៍ បានអះអាងថាលោកមិនជឿថាចាំបាច់ត្រូវមានអ៊ីមុាំទេ ។

ហុីស្សាំ យុវៈនិស្សិតម្នាក់របស់ អ៊ីមុាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ាឌិក صلوات الله عليه والسلام បានសួរអុាំរ៍ថាបើលោកជឿជាក់យ៉ាងមាំថាមិនចាំបាច់ត្រូវមានអ៊ីមុាំទេនោះ តើលោកអាចឆ្លើយសំណួរមួយចំនួនបានទេ ។ អុាំរ៍យល់ព្រម ។

ហុីស្សាំបានសួរអុាំរ៍ថាតើលោកមានភ្នែកទេ លោកបានតបថាមាន ។

ហ្វ៊ុស្នាំបានសួរថាតើភ្នែកមានប្រយោជន៍អ្វីទៅ អ៊ុំរ៍បានតបថាភ្នែកមានប្រយោជន៍សម្រាប់មើល ។

ហ្វ៊ុស្នាំបានសួរអ៊ុំរ៍ថាតើលោកមានត្រចៀកទេ លោកបានតបថាមាន ។

ហ្វ៊ុស្នាំបានសួរថាតើត្រចៀកមានប្រយោជន៍អ្វីទៅ អ៊ុំរ៍បានតបថាត្រចៀកមានប្រយោជន៍សម្រាប់ស្តាប់ ។

ហ្វ៊ុស្នាំបានសួរបន្តទៀតអំពីច្រមុះ បន្ទាប់ពីនោះមាត់ ដូចមុនៗដែរ អ៊ុំរ៍បានឆ្លើយដោយគិតថាទាំងនេះជាសំណួរភ្លីភ្លើដែលគេសួរលោក ។

បន្ទាប់មក ហ្វ៊ុស្នាំបានសួរថាតើលោកមានខួរក្បាលទេ អ៊ុំរ៍បានតបថាមាន ។

ហ្វ៊ុស្នាំបានសួរអំពីអត្ថប្រយោជន៍របស់ខួរក្បាលលោក អ៊ុំរ៍បានតបថាខួរក្បាលយល់នូវអ្វីៗដែលអវយវៈដទៃទទួលដឹង ។

ហ្វ៊ុស្នាំបានសួរអ៊ុំរ៍ថាតើមានន័យថា ទោះបីអវយវៈដទៃ (ភ្នែក ត្រចៀក ច្រមុះ មាត់) ជា មិនឈឺក៏ដោយ ក៏មិនអាចធ្វើអ្វីកើតបើគ្មានខួរក្បាលនោះមែនទេ ។ អ៊ុំរ៍យល់ស្រប ។

ហ្វ៊ុស្នាំបន្តទៀតថា ដែលអល់ឡោះហ្វ៍បានបង្កើតខួរក្បាលមកនោះក៏ព្រោះតែដើម្បីគ្រប់គ្រងអវយវៈឯទៀត តើអ៊ុំរ៍មិនដែលគិតទេឬ ថាអល់ឡោះហ្វ៍ចាត់តាំងមគ្គុទេសក៍ (អ៊ីម៉ាំ) មួយរូបដើម្បីបង្ហាញផ្លូវនិងដឹកនាំមនុស្ស ?

អ៊ុំរ៍ឆ្លើយមិនរួច ។

ព្រះសាស្តាយើងមានព្រះវចនៈថា៖ "អ្នកណាស្រឡាញ់អាស្ហ៍លុល-បៃត៍យើង អ្នកនោះប្រៀបបាននឹងអ្នកដែលឡើងទៅលើនាវារបស់នុះហ្វ៍ﷺ ពួកគេនឹងត្រូវសង្គ្រោះឲ្យផុតពីភ្លើងនរក ។"

## កិច្ចការសិស្ស ៦

ចូរបំពេញបុរាខ្ទិស្ឋព្រះសាស្តាយើង៖

អ្នកណា_________ _________យើងអ្នកនោះប្រៀបបាននឹងអ្នកដែល_________
លើនាវារបស់_________ ពួកគេនឹងត្រូវ_________ពីភ្លើង_________ ។



ចូរសរសេរព្រះនាមរបស់អាអ៊ីមាសូ (គឺអ៊ីមុាំទាំងអស់) នៅក្នុងក្របខាងក្រោមនេះ ។

**មេរៀនទី ៧**

# គ្នីយ៉ាម៉ាត្ទ

គ្នីយ៉ាម៉ាត្ទ ឬ គ្នីយ៉ាម៉ាស្ទ (القيامة) គឺជំនឿលើថ្ងៃជុំនំជម្រះ ។

គឺថ្ងៃដែលយើងនឹងត្រូវទទួលខុសត្រូវលើទង្វើទាំងអស់របស់យើង ដែលយើងធ្វើក្នុងលោកនេះ ។ អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងព្រះមហាគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៍អាល់-មុលក៍ ថា៖

*"ព្រះអង្គបានបង្កើតការស្លាប់និងការរស់រានមានជិវិត ដើម្បីពិសោធឲ្យដឹងថាអ្នកណាខ្លះក្នុងចំណោមពួកអ្នកប្រព្រឹត្តល្អជាងគេ ។" (៦៧:២)*

ហេតុអ្វីគ្នីយ៉ាម៉ាត្ទ ?

១-អល់ឡោះហ្វ៍មិនបានបង្កើតយើងមកដោយឥតសារប្រយោជន៍ទេ ដើម្បីជាទីបញ្ចប់របស់យើងពេលណាយើងស្លាប់ ។ ពិភពលោកមិនមែនឥតគោលដៅទេ ។ ចូរអ្នកនឹកស្មានថាអ្នកជាវិចិត្រករមួយរូបដែលគូរគំនូរឡើង ដើម្បីតែកម្ទេចវាចោលប៉ុណ្ណោះបន្ទាប់ពីគូររួច ។

២-តុលាការអល់ឡោះហ្វ៍ (ឬ យុត្តិធម៌អល់ឡោះហ្វ៍) ។ ជនឧក្រិដ្ឋទាំងអស់មិនទទួលខុសត្រូវទង្វើខ្លួនឯងទេក្នុងលោកនេះ ។ ជួនកាលពួកគេរួចខ្លួន ។ ដូចគ្នាដែរ ទង្វើល្អមិនបានទទួលការតបស្នងទាំងអស់ទេក្នុងលោកនេះ ឧទាហរណ៍ សាងសង់ម៉ាស់យ៊ិដ្ទ បង្ហាត់បង្រៀនកុមារ ។

តើអល់ឡោះហ្វ៍នឹងបង្កើតយើងសាឡើងវិញដូចម្ដេចទៅ ពេលដែលយើងទៅជាធូលីហើយនោះ ?
អល់ឡោះហ្វ៍មានព្រះបន្ទូលក្នុងព្រះមហាគម្ពីរគួរអាន (ស៊ូរ៉ោះត៍ ក្វហ្វ ៥០:១៥) ថា៖

*"តើយើងហត់នឿយឬទេ ក្នុងការបង្កើតដំបូង[នូវសត្វលោក]នោះ? តែពួកគេនៅក្នុងការសង្ស័យ[អំពីរឿងទាក់ទងនឹង]ការបង្កើតថ្មី (ការឲ្យរស់ពីស្លាប់ឡើងវិញ) ។"*

អាយ៉ាស់ខាងលើនេះឲ្យយើងដឹងថា ដូចអល់ឡោះហ្វបានបង្កើតយើងនាដើមដំបូងនៃជីវិតយើងដែរ ព្រះអង្គនឹងឲ្យយើងមានជីវិតឡើងវិញ ។
ចូរអ្នកចងចាំថាយើងត្រូវបង្កើតមកនៅដើមដំបូងបង្អស់ យើងត្រូវបង្កើតមកពីភាពទទេ គ្មានអ្វីសោះឡើយ ។

## បរលោក

អល់ឡោះហ្វមានព្រះបន្ទូលនៅក្នុងព្រះមហាគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាស់-សាច់ដាស់ (៣២:១៧) ថា ៖

*ពុំមានអ្នកណាមួយអាចដឹងបានឡើយថា គេបម្រុងទុកនូវសេចក្ដីរីករាយណាខ្លះទេសម្រាប់ខ្លួនអ្នកនោះ ដែលជាការតបស្នងទង្វើដែលពួកគេបានប្រព្រឹត្ត ។*

ត្រង់នេះ គេឲ្យយើងដឹងថាអ្វីដែលយើងនឹកស្មានថាអស្ចារ្យនោះនឹងមិនស្មើឋានសួគ៌បរមសុខទេ ។ ឋានសួគ៌បរមសុខប្រសើរបំផុត ។ យើងមិនអាចប៉ាន់ស្មានបានថានឹងអស្ចារ្យប៉ុណ្ណាទេ ។

ដូចគ្នាដែរ យើងមិនអាចប៉ាន់ស្មានបានថាឋាននរកនឹងអាក្រក់ប៉ុណ្ណាទេ ។ អល់ឡោះហ្វមានព្រះបន្ទូលនៅក្នុងព្រះមហាគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាក់ឡា (៨៧:១៣) ថា ៖

*នៅក្នុងភ្លើងនរកនោះ គេនឹងមិនស្លាប់ទេ ហើយក៏មិនរស់ទេដែរ ។*

គេបានសួរ អ៊ីម៉ាំ ទី ៦ គឺអ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វឌិក្ក صلوات الله عليه والسلام អំពីអត្ថន័យរបស់អាយ៉ាស់នេះ ។

ព្រះអង្គ صلوات الله عليه والسلام បានឆ្លើយថា អល់ឡោះហ្ទ៍បានប្រាប់យើងអំពីឋាននរក និងហេតុដូចម្ដេចយើងមិនអាចរស់និងមិនអាចស្លាប់បាន ។ ព្រះអង្គ صلوات الله عليه والسلام បានអធិប្បាយថាពេលណាស្បែកនិងខ្លួនយើងត្រូវភ្លើងឆេះ គេនឹងឲ្យយើងមានស្បែកនិងខ្លួនថ្មី ហើយស្បែកនិងខ្លួននោះនឹងឆេះ ។

បុរសនោះបានសួរអ៊ីម៉ាំ صلوات الله عليه والسلام ថា តើស្បែកថ្មីនេះនឹងត្រូវដាក់ទោសក្នុងភ្លើងដូចម្ដេចទៅ ដោយសារតែបាបកម្មដែលស្បែកចាស់បានធ្វើ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានថាស្បែកថ្មីនេះនឹងត្រូវធ្វើឲ្យកើតឡើងវិញដោយស្បែកចាស់ ។ ព្រះអង្គ صلوات الله عليه والسلام លើកជាឧទាហរណ៍នូវដុំឥដ្ឋដែលបែក ហើយទៅជាផង់ គេធ្វើដុំឥដ្ឋឡើងវិញជាមួយផង់ដុំឥដ្ឋចាស់ ។ ដុំឥដ្ឋនេះជាដុំឥដ្ឋថ្មីហើយជាដុំឥដ្ឋចាស់តែម្ដង ។
ដូចគ្នាដែរ ពួកនរកនឹងត្រូវដុតក្នុងភ្លើង លុះពួកគេឆេះអស់គេនឹងបង្កើតពួកគេឡើងវិញដើម្បីនឹងត្រូវគេដុតម្ដងហើយម្ដងទៀតលុះត្រាតែពួកគេជ្រះបាប ។

# កិច្ចការសិស្ស ៧

តើអ៊ីមុាំ យ៉ាក់ហ្វារ អាស្ស៍-ស្វ៍ឌិក្ក صلوات الله عليه والسلام អធិប្បាយម្តេចខ្លះក្នុងការលើកដុំឥដ្ឋជាឧទាហរណ៍ ?



ហេតុអ្វីត្រូវមានគ្វីយ៉ៅម៉ាត្ត់ ?

____________________________________________________________

________________________________

តើអល់ឡោះហ្វ៍នឹងបង្កើតយើងឡើងវិញដូចម្តេច ពេលយើងទៅជាធូលីហើយនោះ ?

________________________________________________________

_____________________________________

តើអល់ឡោះហ្វ៍មានព្រះបន្ទូលថាអ្វីខ្លះអំពីឋានសួគ៌ និង ឋាននរក ?

________________________________________________________

_____________________________________

**មេរៀនទី ៨**

# ហ្វ៊ូរូអ៊ុដឌីន - អារម្ភកថា

ហ្វ៊ូរូអ៊ុដឌីន (فروع الدين) គឺសាខារបស់សាសនា ។

ហ្វ៊ូរូអ៊ុដឌីន មាន ១០ ប្រការគឺ ៖

១) ស្វឡាត់ ។
២) ស្វៅម៍ (صوم) - ត្រណមអាហារ ។
៣) ហ្វាច់ (حج) - ពិធីបូជនីយេសចរណ៍ ។
៤) ស្វាកាត់ (زكاة) - ពន្ធ ។
៥) ឃុមស៍ (خمس) - ពន្ធ ។
៦) ឃ្ជីហ្វាដ្ឋ (جهاد) - សន្តសង្គ្រាម ។
៧) អាំរ៍ ប៊ិល-ម៉ាក់រូហ្វ (امر بالمعروف) - បង្គាប់ឲ្យធ្វើល្អ ។
៨) ណាហ្វ៊ី អ៊ុនីល មុនការ (نهى عن المنكر) - ហាមធ្វើអាក្រក់ ។
៩) តាវ៉ាល់ឡា (تولّى) - រក្សាមិត្តភាពរវាងមិត្តអាស្ហ៍ លុល-បៃត៍ ។
១០) តាបារ៉ (تبرأ) - ប្រឆាំងសត្រូវរបស់អាស្ហ៍ លុល-បៃត៍ ។

ទាំងនេះជាវ៉ាឃ្ជិប ត្រូវតែប្រតិបត្តិតាម ។

ពុំមានតាក់លីដទេ (تقليد ការធ្វើត្រាប់តាម) ក្នុង អ៊ូស្វូល អ៊ុដឌីន (أصول الدين) តែមានតាក់លីដក្នុងហ្វ៊ូរូអ៊ុដឌីន ។

## កិច្ចការសិស្ស ៨

ចូរសរសេរន័យរបស់ហ្វ៊ូរអ៊ុដ្ងឌ្វីននីមួយៗនៅលើដើមឈើខាងក្រោម ។ ចូរទន្ទេញឲ្យចាំ ។



ដូចដើមឈើដែរដែលមានឫសនិងមានមែក ។ ឫសជាគ្រឹះរបស់ដើមឈើដែលបែកមែកសាខា ។ អ៊ីស្លាមស្ថិតនៅលើ អ៊ូស្វូល អ៊ុដ្ឌីន (ឫស ឬ គ្រឹះ) និងលើ ហ្វ៊ូរូអ៊ុដ្ឌីន (សាខា) ។ កាលណាគ្រឹះរឹងមាំ ដោយយល់និងជឿអ៊ូស្វូល អ៊ុដ្ឌីន កាលនោះនឹងមានឡើងនូវទង្វើ ពោលគឺ ហ្វ៊ូរូអ៊ុដ្ឌីន ។

**មេរៀនទី ៩**

# សាឡើងវិញ - សូត្រក្នុងស្ហ៍ឡាត់

១) **គីយ៉ាម**

ខ្ញុំធ្វើស្ហ៍ឡាត់______________________________ _____រ៉ក់អាត់

قُرْبَةً اِلَى اللهِ

ដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្វ ។

اَللهُ اَكْبَرُ

អល់ឡោះហ្វធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

សូត្រស៊ូរ៉ោះត៍ អាល់-ហ្វាទីហ្វាស់ និង ស៊ូរ៉ោះត៍គួរអានមួយទៀត

២) **រូគុអ៍**

سُبْحَانَ رَبِّيَ الْعَظِيْمِ وَ بِحَمْدِهِ

សូមថ្វាយសេចក្តីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ធំធ្ងើង សូមថ្វាយសេចក្តីសរសើរទាំងអម្បាលម៉ានចំពោះព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

ឱអល់ឡោះហ្វ! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ﷺ ។

៣) **គីយ៉ាម**

سَمِعَ اللهُ لِمَنْ حَمِدَهِ

អល់ឡោះហ្វទ្រង់សវនាការអ្នកសរសើរព្រះអង្គ

اَللهُ اَكْبَرُ

អល់ឡោះហ្ទធំធ្លើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៤) **សាច់ដុាស់**

سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهِ

សូមថ្វាយសេចក្ដីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ខ្ពង់ខ្ពស់ សូមថ្វាយសេចក្ដីសរសើរទាំងអម្បាលម៉ានចំពោះព្រះអង្គ ។

اللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

ឱអល់ឡោះហ្ទ! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ﷺ ។

៥) **យូលុស**

اَللهُ اَكْبَرُ

អល់ឡោះហ្ទធំធ្លើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

اَسْتَغْفِرُ اللهَ رَبِّيْ وَ اَتُوْبُ اِلَيْهِ

ខ្ញុំសូមខមាទោសចំពោះអល់ឡោះហ្ទ ព្រះម្ចាស់ខ្ញុំ ហើយខ្ញុំត្រឡប់មករកព្រះអង្គវិញដោយសូមស្មារលាលែងធ្វើកំហុសទៀត ។

اَللهُ اَكْبَرُ

អល់ឡោះហ្ទធំធ្លើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៦) **សាច់ដុាស់**

سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهِ

សូមថ្វាយសេចក្ដីរុងរឿងចំពោះព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំ ព្រះដ៏ខ្ពង់ខ្ពស់ សូមថ្វាយសេចក្ដីសរសើរទាំងអម្បាលម៉ានចំពោះព្រះអង្គ ។

اللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَاٰلِ مُحَمَّدٍ

ឱអល់ឡោះហ៍ ! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហាំម៉ាដ់ﷺ ។

៧) **យ៉ូលុស**

اَللّٰهُ اَكْبَرُ

អល់ឡោះហ៍ធំធ្ងើងបំផុត (លើសអ្វីៗនិងសព្វសត្វទាំងអស់) ។

៨) ពេលងើបឡើងវិញដើម្បីចាប់ផ្ដើមរ៉ក់អ្កាត់បន្ទាប់៖

بِحَوْلِ اللّٰهِ وَ قُوَّتِهِ اَقُوْمُ وَ اَقْعُدُ

ខ្ញុំក្រោកឡើងនិងអង្គុយអាស្រ័យដោយកម្លាំងនិងឥទ្ធិពលរបស់អល់ឡោះហ៍ ។

៩) ក្នុងរ៉ក់អ្កាត់ទី ២ ពេលឈរគ្វីយ៉ាម (គ្វីរ៉អាត់ قرآت) សូត្រស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៉ាស់ និង អាល់-អ៊ីខ្លាស់ ។

១០) **គ្នូត**

رَبَّنَا اٰتِنَا فِيْ الدُّنْيَا حَسَنَةً وَّ فِيْ الْاٰخِرَةِ حَسَنَةً وَّ قِنَا عَذَابَ النَّارِ

ឱព្រះជាម្ចាស់របស់អស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គព្រះរាជទានឲ្យអស់ទូលព្រះបង្គំជាខ្ញុំនូវសេចក្ដីល្អសម្រាប់លោកនេះនិងលោកមុខ ហើយសូមព្រះអង្គឲ្យអស់ទូលព្រះបង្គំជាខ្ញុំបានរួចផុតពីភ្លើងនរកផង ។

១១) **រូគុអ៊ុ, គ្វីយ៉ាម**
**សាច់ដ្ងាស់, យ៉ូលុស**
**សាច់ដ្ងាស់, យ៉ូលុស**
} ដូចរ៉ក់អ្កាត់ទី ១

១២) ពេលអង្គុយយ៉ូលុស ៖

-តាស្ហាស់ហ៊ូដ បើស៊ូឡាត់ ៣ ឬ ៤ រ៉ក់អាត់ ។
-តាស្ហាស់ហ៊ូដ និង សាឡាម បើស៊ូឡាត់ ២ រ៉ក់អាត់ ។

**តាស្ហាស់ហ៊ូដ**

اَشْهَدُ اَنْ لَا اِلٰهَ اِلَّا اللّٰهُ وَحْدَهُ لَا شَرِيْكَ لَهُ

ខ្ញុំប្តេជ្ញាថាពុំមានព្រះផ្សេងពីអល់ឡោះហ៍ឡើយ ព្រះអង្គឯកឯង ពុំមានសហការីឡើយ

وَ اَشْهَدُ اَنَّ مُحَمَّدًا عَبْدُهُ وَ رَسُوْلُهُ.

ខ្ញុំសូមប្តេជ្ញាថាមូហ្ហាំម៉ាដ់ជាបាវបម្រើរបស់ព្រះអង្គ និងជាសាស្តារបស់ព្រះអង្គ ។

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

ឱអល់ឡោះហ៍ ! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្តីដល់មូហ្ហាំម៉ាដ់ﷺ និងដល់ក្រុមគ្រួសារعليهم السلامរបស់មូហ្ហាំម៉ាដ់ﷺ ។

**សាឡាម**

اَلسَّلَامُ عَلَيْكَ اَيُّهَا النَّبِيُّ وَ رَحْمَةُ اللّٰهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តី (របស់អល់ឡោះហ៍) កើតមានដល់ព្រះអង្គ ឱបណ្តាសាស្តាអើយ ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ៍ និងពរជ័យរបស់ព្រះអង្គ ។

اَلسَّلَامُ عَلَيْنَا وَ عَلٰى عِبَادِ اللّٰهِ الصَّالِحِيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់យើង និងដល់បណ្តាបាវបម្រើមានសទ្ធារបស់អល់ឡោះហ៍ ។

اَلسَّلَامُ عَلَيْكُمْ وَ رَحْمَةُ اللّٰهِ وَ بَرَكَاتُهُ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គទាំងឡាយ (មូហ្ហាំម៉ាដ់និងព្រះរាជកុលដ្ឋានព្រះអង្គ និងបណ្តាសាស្តានិងទេវតា) ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ៍និងពរជ័យរបស់ព្រះអង្គ ។

បន្ទាប់មក សូត្រ ៣ ដង ព្រមទាំងលើកដៃរាល់ដង ថា៖

اَللّٰهُ اَكْبَرُ

អល់ឡោះហ្វ៎ធំធ្ងើងបំផុត ។

បន្ទាប់មកទៀត សូត្រ ៣ ដង ថា៖

اَللّٰهُمَّ صَلِّ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

ឱអល់ឡោះហ្វ៎! សូមព្រះអង្គព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ្ឋ ﷺ និងដល់ក្រុមគ្រួសារ عليهم السلام របស់មូហាំម៉ាដ្ឋ ﷺ ។

១៣) ក្នុងរ៉ក់អាត់ទី ៣ និង ទី ៤ នៅពេលឈរត្រង់យ៉ាម អ្នកត្រូវសូត្រ តាស់បីហ្វាត់អារបាអាស់ (تسبيحات اربعه) ៣ ដង គឺ៖

سُبْحَانَ اللّٰهِ وَ الْحَمْدُ لِلّٰهِ وَ لَا اِلٰهَ اِلَّا اللّٰهُ وَ اللّٰهُ اَكْبَرُ

សូមថ្វាយសេចក្ដីសរសើរចំពោះអល់ឡោះហ្វ៎ សូមថ្វាយសេចក្ដីរុងរឿងចំពោះអល់ឡោះហ្វ៎ មិនមានព្រះផ្សេងពីអល់ឡោះហ្វ៎ឡើយ អល់ឡោះហ្វ៎ធំធ្ងើងបំផុត ។

# កាយវិការក្នុងស្វ៏ឡាត់



តាក់បីរ៉ទុល អិះហ្រ៉ាម គ្វីយ៉ាម រុគុអ៊ុ គ្វីយ៉ាម សាច់ដ្ជាស់ យ្ជុលុស សាច់ដ្ជាស យ្ជុលុស



គ្វីយ៉ាម គុនូត រុគុអ៊ុ គ្វីយ៉ាម សាច់ដ្ជាស់ យ្ជុលុស សាច់ដ្ជាស់



យ្ជុលុស (ចប់)



តាក់បីរ៉ទុល អិះហ្រ៉ាម គ្វីយ៉ាម រុគុអ៊ុ គ្វីយ៉ាម សាច់ដ្ជាស់ យ្ជុលុស សាច់ដ្ជាស់



យ្ហុលុស គ្ហីយ៉ាម គ្ហូនូត រ្ហុគុអ៍ គ្ហីយ៉ាម សាច់ដ្ជាស់ យ្ហុលុស



សាច់ដ្ជាស យ្ហុលុស (ចប់)

**មេរៀនទី ១០**

# នៀត

នៀត (نِيّة) គឺបំណងរបស់អ្នក អ្វីដែលអ្នកនឹងធ្វើ ។

មុននឹងធ្វើអ្វីក៏ដោយ អ្នកត្រូវនៀតជាទម្លាប់ ទោះបីទង្វើនោះជាទង្វើធម្មតាក៏ដោយ (ឧទាហរណ៍ បរិភោគ ជាដើម) ។

ទង្វើដែលអ្នកនៀតធ្វើនោះ គម្បីធ្វើដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្ គឺៈ "គួរបាតាន់ អ៊ីលឡុលឡោះហ្" ។

ធ្វើដូច្នេះអ្នកនឹងទទួលបាននូវស្វាវ៉ាប់ក្នុងគ្រប់ទង្វើ ។

ចូរអ្នកចងចាំថា នៀតរបស់អ្នកចាំបាច់ត្រូវស្មោះត្រង់ ដូច្នេះបើអ្នកធ្វើដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ្ អ្នកគប្បីធ្វើទង្វើស៊ូណាត់ទាំងអស់ ។

ក្នុងទង្វើមួយចំនួន នៀតជាវ៉ាយិប (អ្នកចាំបាច់ត្រូវតែធ្វើ) ឧទាហរណ៍ ស្ឡ់ឡាត់ ។
មុននឹងចាប់ផ្តើមធ្វើស្ឡ់ឡាត់ អ្នកចាំបាច់ត្រូវតែនៀត ។

ក្នុងពេលនៀត អ្នកចាំបាច់ត្រូវតែ ៖

១) ថាឈ្មោះស្ឡ់ឡាត់ដែលអ្នកចង់ធ្វើ ។

២) ថាតើស្ឡ់ឡាត់នោះជាវ៉ាយិប ឬ ជាស៊ូណាត់ ។

៣) ថាតើស្ឡ់ឡាត់នោះជាអាដាអ៍ (اداء ក្នុងពេលកំណត់) ឬ ជាក៏ដ៏ (قضي ក្រៅពេលពោលគឺ សង) ។

៤) ស្វ៊ឡាត់ត្រូវតែ "គ្ហូរបាតាន់ អ៊ីលឡុលឡោះហ្វ៍"

៥) នៀតចាំបាច់ត្រូវតែដដែលដូចដើមលុះចប់ស្វ៊ឡាត្ត់ ។ បើនៀតរបស់អ្នកមិនមែននៀតដើម្បីអល់ឡោះហ្វ៍ទេ ព្រះអង្គមិនទទួលស្វ៊ឡាត្ត់របស់អ្នកទេ ។

សម័យថ្ងៃមួយ បុរសអ្នកសទ្ធាសប់ចិត្តម្នាក់តែងតែភ្ញាក់ពីដំណេកមុនពេលស្វ៊ឡាត្ត់អាល់-ហ្វាច៉្រដើម្បីធ្វើស្វ៊ឡាត្ត់ តាហ្វាច៉ុយ៉ុដ្ធ (تهجد) ។

ថ្ងៃមួយ កំពុងតែធ្វើស្វ៊ឡាត្ត់ក្នុងម៉ាស់យ៊ិដ្ធ គាត់បានឮស្នូរនៅក្រោយខ្នងគាត់ ។ គាត់នឹកក្នុងចិត្តថាមានគេចូលមកក្នុងម៉ាស់យ៊ិដ្ធ គាត់ក៏បានចាប់ផ្ដើមបំពេញស្វ៊ឡាត្ត់យឺតៗដោយផ្ចិតផ្ចង់ ដើម្បីសម្ញែងអ្នកដែលទើបនឹងចូលមកក្នុងម៉ាស់យ៊ិដ្ធ ។

បុរសរូបនេះបានបំពេញស្វ៊ឡាត្ត់យ៉ាងយកចិត្តទុកដាក់ យ៉ាងយឺតៗ ដោយប្រយ័តប្រយែងក្នុងការសូត្រឲ្យបានច្បាស់គ្រប់ម៉ាត់ ឲ្យត្រឹមត្រូវតាមម៉ាក់រ៉ូច្ច តម្រូវឲ្យគាត់ប្រើពេលយូរជាងធម្មតាពីរដង ។

លុះចប់ គាត់បានក្រឡេកទៅមើលថាតើអ្នកណាបានចូលមកក្នុងម៉ាស់យ៊ិដ្ធ ។ គាត់បានឃើញឆ្កែកំពុងតែអង្គុយនៅទីនោះ ។

បុរសរូបនេះបានងើបតាំងពីព្រលឹម បានខិតខំចំណាយពេលព្យាយាមក្នុងការបំពេញស្វ៊ឡាត្ត់ នៅទីបំផុតការប្រឹងប្រែងរបស់គាត់គឺដើម្បីឆ្កែ ។

ដើម្បីនឹងដឹងថាតើនៀតរបស់អ្នក "គ្ហូរបាតាន់ អ៊ិលឡុលឡោះហ្វ៍" ឬទេ ចូរអ្នកសម្គាល់មើលខ្លួនអ្នកធ្វើស្វ៊ឡាត្ត់ដូចម្ដេចខ្លះពេលអ្នកនៅឯផ្ទះតែម្នាក់ឯង និងពេលអ្នកនៅឯម៉ាស់យ៊ិដ្ធពេលដែលមនុស្សសម្លឹងមើលមកអ្នក ។ បើសិនជាស្វ៊ឡាត្ត់ទាំងពីររបស់អ្នកខុសគ្នា បានសេចក្ដីថានៀតរបស់អ្នកមិន "គ្ហូរបាតាន់ អ៊ិលឡុលឡោះហ្វ៍" ទេ ។

ចូរអ្នកចងចាំថា អ្នកមិនបានស្វាវ៉ាប់ទេបើអ្នកធ្វើដើម្បីអ្នកណាផ្សេងពីអល់ឡោះហ្វ៍ ។

# កិច្ចការសិស្ស ១០

ចូរគូរនៅខាងក្រោមនេះអ្វីដែលបុរសរូបនោះបានធ្វើដើម្បីឆ្កែ ។



ហេតុអ្វីបុរសមិនទទួលបាននូវស្នារ៉ាប់ ?

______________________________________________

_____________________________

តើនៀតមានន័យថាអ្វី ?

______________________________________________

_____________________________

តើ "គូរបាតាន់ អ៊ិលឡុលឡោះហ្វ៍" មានន័យថាអ្វី ?

______________________________________________

_____________________________

តើអ្នកចាំបាច់ត្រូវនៀតនៅពេលណា ?

______________________________________________

_____________________________

**មេរៀនទី ១១**

# គ្ហីបឡាស្ហ៍

គ្ហីបឡាស្ហ៍ (قبلة) គឺទិសដែលយើងបែរទៅរកពេលយើងធ្វើនមស្ការបូជាអល់ឡោះហ្ហ៍ (ស្ហ៍ឡាត្ហ៍) ។

គ្ហីបឡាស្ហ៍របស់យើងគឺ កាក់ហ្ហ៍បាស្ហ៍ "ផ្ទះអល់ឡោះហ្ហ៍" (بيت الله) ។

កាក់ហ្ហ៍បាស្ហ៍នៅក្នុង ម៉ាស់យ៉ីឌុល ហ្ហារ៉ម (المسجد الحرام) នៅឯម៉ាក់កាស្ហ៍ (مكة) ។

កាលដែលអល់ឡោះហ្ហ៍បានដាក់បញ្ជាឲ្យព្រះសាស្ដាﷺ និងបណ្ដាមុស្លីមធ្វើនមស្ការ (ស្ហ៍ឡាត្ហ៍) ប្រចាំថ្ងៃនាគ្រាដំបូង ពួកគេបានបែរមុខទៅរក បៃទុល មូក្ហទ្ហ៍ឌីស (بيت المقدس យេរូសាលិម) ។ គេបានធ្វើដូច្នេះតរៀងមករហូតដល់ខែទី ១៧ ក្រោយ ហ្ហ៊ីជ្ហរ៉ោះត្ហ៍ (هجرة) ។

ថ្ងៃមួយ ពេលដែលព្រះសាស្ដាﷺនិងបណ្ដាមុស្លីមកំពុងតែបំពេញស្ហ៍ឡាត្ហ៍រួមគ្នា ព្រះបញ្ញត្តិអល់ឡោះហ្ហ៍បានដាក់មកថាឲ្យផ្លាស់គ្ហីបឡាស្ហ៍ពី បៃទុល មូក្ហទ្ហ៍ឌីស ទៅរក ព្រះមហាគ្រឹះ កាក់ហ្ហ៍បាស្ហ៍ វិញ ។

បន្ទាប់ពីព្រះសាស្ដាﷺបានបំពេញស្ហ៍ឡាត្ហ៍ពីររ៉ក់អាត្ហ៍ ទេវតាយ៉ីបរ៉អ៊ីល عليه السلام បាននាំព្រះរាជសាររបស់អល់ឡោះហ្ហ៍ عز وجل មកឲ្យព្រះអង្គﷺ ។ ព្រះអង្គ عليه السلام បានចាប់ដៃព្រះសាស្ដាﷺ ហើយបានបំបែរព្រះអង្គﷺទៅរកព្រះមហាគ្រឹះ កាក់ហ្ហ៍បាស្ហ៍ ឯ ម៉ាស់យ៉ីឌុល ហ្ហារ៉ម នានគរម៉ាក់កាស្ហ៍ ។

ព្រះសាស្ដាﷺបានផ្លាស់ទិសភ្លាម កណ្ដាលស្ហ៍ឡាត្ហ៍តែម្ដង ។ អ៊ីម៉ាំអាលី صلوات الله عليه والسلام បានផ្លាស់ប្ដូរតាមភ្លាមដែរ ។ មុស្លីមឯទៀតស្រឡាំងកាំងដោយសារទង្វើនេះ អ្នកខ្លះបានធ្វើតាមដូចអ៊ីម៉ាំអាលី صلوات الله عليه والسلام ដែរ ។

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលក្នុងគួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ ២:១៤២) ថា៖ *"មនុស្សត្លីត្លើក្នុងចំណោមបណ្ដាមនុស្សនឹងនិយាយថា៖ "អ្វីជាមូលហេតុបណ្ដាលឲ្យពួកគេ (ពួកមុស្លិម) បែរចេញពីទិស (គិបឡាស់) ដែលពួកគេធ្លាប់បែរទៅរក[ពេលធ្វើនមស្ការ] កាលពីមុន ?" ចូរអ្នកថ្លែង[ឲ្យពួកគេជ្រាប]ថា៖ "ទិសខាងកើតនិងទិសខាងលិចជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ ។ ព្រះអង្គសព្វព្រះហឫទ័យដឹកនាំបុគ្គលណាឆ្ពោះទៅរកផ្លូវត្រឹមត្រូវស្រេចតែលើព្រះអង្គ ។""*

ព្រឹត្តិការណ៍នេះបានកើតឡើងនៅឯម៉ាស់យ៉ិដមួយ ដែលគេស្គាល់ឈ្មោះថា ម៉ាស់យ៉ីដ អាល់-គីបឡាតៃន៍ (المسجد القبلتين) ដែលនៅឯម៉ាឌីណាស់ (المدينة) ។

ព្រះសាស្ដាﷺបានបែរទៅរកគីបឡាស់ថ្មីដោយឥតរួញរា ។ នេះគឺហេតុការណ៍អស្ចារ្យមួយរបស់ព្រះសាសាﷺ ដែលបានបែរមុខទៅរកព្រះមហាគ្រឹះ កាក់បាស់ ដោយឥតបានប្រើឧបករណ៍វិទ្យាសាស្ត្រណាមួយឡើយ (ឧទាហរណ៍ ត្រីវិស័យជាដើម) ។

សព្វថ្ងៃនេះ គេអាចរកគីបឡាស់ (ទិសស៊ូឡាត់) ឃើញ ៖
១-ដោយសាកសួរប្រជារាស្ត្រ ។
២-ដោយប្រើត្រីវិស័យនិងកូនសៀវភៅដែលមាននូវសេចក្ដីបញ្ជាក់ ។
៣-នៅក្នុងម៉ាស់យ៉ិដ អាស្រ័យលើ មិះហ្រ៉ាប (مِحْراب កន្លែងលុងចង្អុលបង្ហាញទិសស៊ូឡាត់)
៤-ដោយអាស្រ័យលើផ្នូរមុស្លីម (គេកប់សពដោយដាក់ផ្ដេកលើខាងស្ដាំខ្លួន បែរមុខទៅរកគីបឡាស់) ។

បើអ្នកមិនស្គាល់ទិសគីបឡាស់ទាល់តែសោះ ហើយមិនមានមធ្យោបាយរកឃើញទេ អ្នកគប្បីបំពេញស៊ូឡាត់ដោយបែរទៅរកទិសទាំងបួន ។

បើអ្នកបានបំពេញស៊ូឡាត់ដោយបែរទៅរកទិសណាមួយ ក្រោយមកអ្នកបានដឹងថាទិសនោះមិនត្រឹមត្រូវទេ អ្នកគប្បីបំពេញស៊ូឡាត់សាឡើងវិញ បើសិនជាអ្នកបានបំពេញស៊ូឡាត់នោះ ដោយបែរចេញពីគីបឡាស់ពិតលើសពី ៩០ អង្សា ។

# កិច្ចការសិស្ស ១១



តើគិ្ញបឡាស្ល់មានន័យថាអ្វី ?

______________________________

ឯណាគិ្ញបឡាស្ល់របស់អ្នក ?

______________________________

តើគិ្ញបឡាស្ល់មុនដំបូងរបស់បណ្ដាមុស្លីមគឺអ្វី ?

______________________________

តើការផ្លាស់ប្ដូរគិ្ញបឡាស្ល់បានប្រព្រឹត្តឡើងនៅឯម៉ាស់យ៊ិដ្ឋណា ?

______________________________

តើព្រះសាស្ដាﷺកំពុងតែធ្វើអ្វី ពេលដែលព្រះអង្គﷺបានទទួលព្រះរាជបញ្ជាឲ្យផ្លាស់គិ្ញបឡាស្ល់ ?

______________________________

**មេរៀនទី ១២**

# ពេលវេលាសឹ្វឡាត់

សឹ្វឡាត់នីមួយសុទ្ធតែមានពេលវេលាពិសេសរបស់វា ។

អល់ឡោះហ្វមានព្រះបន្ទូលក្នុងគួរអាន (ស៊ូរ៉ោះត៍ បានី-អ៊ីសរ៉អ៊ីល ១៧:៧៨) ថា៖

*"ចូរអ្នកធ្វើនមស្ការពីពេលថ្ងៃជ្រេរហូតដល់ពេលងងឹតនៃពេលយប់ និង[ចូរអ្នក]សូត្រពេលមុនថ្ងៃរះ (ធ្វើនមស្ការបូជាអល់ឡោះហ្វពេលមុនថ្ងៃរះ សូត្រគួរអាន) ។ ព្រោះការសូត្រ (ធ្វើនមស្ការបូជាអល់ឡោះហ្វពេលមុនថ្ងៃរះ សូត្រគួរអាន) ពេលមុនថ្ងៃរះនោះមានបណ្ដាសាក្សី (ទេវតា) ។" [១៧:៧៨]*

អាយ៉ាស់ខាងលើនេះបញ្ជាក់ឲ្យយើងដឹងថា ពេលវេលារបស់សឹ្វឡាត់គឺមាន ៖

-ពេលថ្ងៃជ្រេ គឺពេលរបស់សឹ្វឡាត់ ហ្ស៊ូហ្វូរ៍ និងសឹ្វឡាត់ អាស្វ៊រ៍ ។
-ពេលងងឹតនៃពេលយប់ គឺពេលសឹ្វឡាត់ ម៉ាក់រីប និង សឹ្វឡាត់ អ៊ីស្ហាអ៍ ។
-ពេលមុនថ្ងៃរះ គឺពេលសឹ្វឡាត់ ហ្វាជ់រ៍ ។

អធិប្បាយលំអិតអំពីពេលវេលា៖

១-សឹ្វឡាត់ ហ្វាជ់រ៍ ។ ចាប់ពីពេលមុនថ្ងៃរះពិតប្រាកដ (ស៊្ហុបហ្ វ សឹ្វឌិក) រហូតដល់ពេលថ្ងៃរះ ។

២-សឹ្វឡាត់ ហ្ស៊ូហ្វូរ៍ ។ ចាប់ពីពាក់កណ្ដាលថ្ងៃ (គឺរវាងថ្ងៃជ្រេនិងថ្ងៃលិច) រហូតដល់ពេលដែលអាចបំពេញសឹ្វឡាត់ ៤ រ៉ក់អាត់បាន (សឹ្វឡាត់ អាស្វ៊រ៍) មុនថ្ងៃលិច ។

៣-សឹ្វឡាត់ អាស្វ៊រ៍ ។ ចាប់ពីពេលដែលអាចបំពេញសឹ្វឡាត់ ៤ រ៉ក់អាត់បាន (សឹ្វឡាត់

ស្មុស្វរ៍) ក្រោយពីពាក់កណ្ដាលថ្ងៃរហូតដល់ថ្ងៃលិច ។

៤-ស្វ៏ឡាត់ ម៉ាក់រីប ។ ចាប់ពីពេលថ្ងៃលិច (គឺអស់ព័ណ៌ក្រហមពីទិសខាងកើត) រហូតដល់ពេលដែលអាចធ្វើស្វ៏ឡាត់ ៤ រ៉ក់អាត់បាន (ស្វ៏ឡាត់ អ៊ីស្សាអ៍) មុនពាក់កណ្ដាលយប់ (រវាងថ្ងៃលិចនិងពេលថ្ងៃរះ) ។

៥-ស្វ៏ឡាត់ អ៊ីស្សាអ៍ ។ ចាប់ពីពេលដែលអាចធ្វើស្វ៏ឡាត់ ម៉ាក់រីប បាន (គឺស្វ៏ឡាត់ ម៉ាក់រីបទាន់ពេលកំណត់ភ្លាមៗ) រហូតដល់ពាក់កណ្ដាលយប់ ។

សព្វថ្ងៃនេះ គេមានកូនសៀវភៅ ឬតារាងប្រាប់ពេលវេលាបំពេញស្វ៏ឡាត់ដែលប្រើទិន្នន័យវិទ្យាសាស្ត្រសម្រាប់គណនាយ៉ាងល្អិតល្អន់ ។

អ្នកអាចកត់សម្គាល់ឃើញថាមានបីអំឡុងពេលសម្រាប់បំពេញស្វ៏ឡាត់ ទោះបីយើងមានប្រាំស្វ៏ឡាត់វ៉ាយិបក្នុងមួយថ្ងៃក៏ដោយ ។ នេះពីព្រោះវាជាការប្រសើរបំផុតដែលបំពេញស្វ៏ឡាត់នៅពេលដែលពេលវេលារបស់វាចូលមកដល់ភ្លាមៗ ។ ព្រោះតែកំណត់ពេលរបស់ស្វ៏ឡាត់ អាស្វ៉រ៍ ចូលមកដល់ក្រោយពីបានបំពេញស្វ៏ឡាត់ ស្មុស្វរ៍រួចភ្លាម បានជាត្រូវបំពេញស្វ៏ឡាត់ អាស្វ៉រ៍ ក្រោយស្វ៏ឡាត់ ស្មុស្វរ៍ ។

ដូចគ្នាដែរសម្រាប់ស្វ៏ឡាត់ ម៉ាក់រីប និងស្វ៏ឡាត់ អ៊ីស្សាអ៍ ។ គេអាចបំពេញស្វ៏ឡាត់ អ៊ីស្សាអ៍ ក្រោយស្វ៏ឡាត់ ម៉ាក់រីប បាន ។

ដូច្នេះ ស្វ៏ឡាត់ ស្មុស្វរ៍ និង ស្វ៏ឡាត់ អាស្វ៉រ៍ នៅក្នុងអំឡុងពេលតែមួយ ឯស្វ៏ឡាត់ ម៉ាក់រីប និង ស្វ៏ឡាត់ អ៊ីស្សាអ៍ ក៏នៅក្នុងអំឡុងពេលតែមួយដែរ ។ ដោយរាប់អំឡុងពេលរបស់ ស្វ៏ឡាត់ ហ្វាច់រ៍ បញ្ចូលផង ទាំងអស់មានបីអំឡុងពេលក្នុង ២៤ ម៉ោង ។

ទោះបីអល់ឡោះហ្វ៏ﷻទុកចន្លោះពេលដ៏យូរឲ្យយើង ដើម្បីបំពេញរាល់ស្វ៏ឡាត់ទាំងនេះក៏ដោយ ក៏យើងត្រូវតែព្យាយាមបំពេញស្វ៏ឡាត់នៅពេលដែលពេលកំណរបស់វាមកដល់ភ្លាម (ដើមពេលវេលា=អាវ៉ាល់ អាល់-វ៉ាក់ទូ) ពីព្រោះមិនសមរម្យទេដែលយើងបន្លាយពេលឲ្យស្ទើរតែផុតអំឡុងពេលទើបអរព្រះគុណអល់ឡោះហ្វ៏ ដែលព្រះអង្គបានប្រោសប្រណីយើងគ្រប់វិស័យ ។

## កិច្ចការសិស្ស ១២

ចូរគូសពេលរបស់ស្វ៍ឡាត់នីមួយៗនៅលើរង្វង់មូលនេះ ។




ចូរសរសេរម៉ោងរបស់ស្វ៍ឡាត់នីមួយៗប្រចាំមួយអាទិត្យ

| | ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| ហ្វាច់រ៍ | | | | | | | |
| ស៊ុស្ហរ៍ | | | | | | | |
| អ៊ាស់រ៍ | | | | | | | |
| ម៉ាក់រីប | | | | | | | |
| អ៊ីស្ហាអ៊ | | | | | | | |

**មេរៀនទី ១៣**

# តាក់គ្មីបាត់ - តាស់ប៊ិះហ្វ - ស៊ីយ៉ារ៉ត់

តាក់គ្មីបាត់ (تعقيبات) គឺការសូត្រគួរអាន ឌូអាក់ និង ស៊ីយ៉ារ៉ត់ (زيارة) ក្រោយស្ឡាត់រួច ។

តាស់ប៊ិះហ្វ (تسبيح) ដែលយើងសូត្រក្រោយស្ឡាត់រួចជាតាស់ប៊ិះហ្វដែលគេស្គាល់ថាជាតាស់ប៊ិះហ្វរបស់ប៊ីប៊ីហ្វាទីម៉ាស់ អាស់-ស្ហារ៉អ៊ ﷺ ព្រោះព្រះនាងបានទទួលជាអំណោយមកពីព្រះសាស្តាមូហាំម៉ាដ់ ﷺ ព្រះបិតាព្រះនាង ﷺ ។

ស្ឡាត់ជាផ្កាស្អាតមួយទង ឯតាស់ប៊ិះហ្វរបស់ប៊ីប៊ីហ្វាទីម៉ាស់ អាស់-ស្ហារ៉អ៊ ﷺ ធ្វើឲ្យផ្កាមួយទងនេះមានក្លិនក្រអូប ។

ដូច្នេះ ក្រោយរាល់ស្ឡាត់យើងគប្បីសូត្រតាស់ប៊ិះហ្វព្រោះយើងចង់ឲ្យស្ឡាត់យើងដូចផ្កាដែលមានក្លិនក្រអូបដែរ ។

តាស់ប៊ិះហ្វរបស់ប៊ីប៊ីហ្វាទីម៉ាស់ អាស់-ស្ហារ៉អ៊ ﷺ គឺ៖

-اَللّٰهُ اَكْبَرُ (អល់ឡោះហ្វទ្រង់មហាធំថ្កើង) ៣៤ ដង ។

-اَلْحَمْدُ لِلّٰهِ (សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្វ) ៣៣ ដង

-سُبْحَانَ اللّٰهِ (សូមថ្វាយសេចក្តីរុងរឿងចំពោះអល់ឡោះហ្វ) ៣៣ ដង

បន្ទាប់មក អ្នកគប្បីស៊ូយ៉ូដមួយដងដើម្បីអរព្រះគុណអល់ឡោះហ្វដែលព្រះអង្គបានប្រទានអ្វីៗឲ្យអ្នកនិងដើម្បីថ្វាយព្រះអង្គនូវសេចក្តីប៉ងប្រាថ្នារបស់អ្នក ។

នៅទីបញ្ចប់ អ្នកគប្បីងើបឈរដើម្បីសូត្រស៊ីយ៉ារ៉ត់ដែលមានបីប៉ែកគឺ ៖
១) ស៊ីយ៉ារ៉ត់ អ៊ីម៉ាំ ហ៊្សៃន៍ صلوات الله عليه والسلام ព្រោះអង្គជាអគ្គមហាប្រមុខនៃបណ្តាជនលះបង់ជីវិត
២) ស៊ីយ៉ារ៉ត់ អ៊ីម៉ាំ អាលី អារ-រីឌ្ហ៍ صلوات الله عليه والسلام ព្រោះសពព្រះអង្គត្រូវបញ្ចុះឆ្ងាយពីស្រុកព្រះអង្គ (ជនបរទេសក្នុងចំណោមជនបរទេស - ក៏រីប អាល់-គូរបា)
៣) ស៊ីយ៉ារ៉ត់ អ៊ីម៉ាំ ម៉ូហ៊ាំម៉ាដ់ អាល់-ម៉ាស្ឌី صلوات الله عليه والسلام ព្រោះព្រះអង្គជាអ៊ីម៉ាំរបស់សម័យកាលយើង ។

## ស៊ីយ៉ារ៉ត់ អ៊ីម៉ាំ ហ៊្សៃន៍ صلوات الله عليه والسلام

اَلسَّلامُ عَلَيْكَ يا اَبا عَبْدِ اللّٰهِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱ អាបា អាប់ឌិលឡាស់

اَلسَّلامُ عَلَيْكَ يَا بْنَ رَسُولِ اللّٰهِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុត្ររបស់ព្រះសាស្តាអល់ឡោះហ៍

اَلسَّلامُ عَلَيْكَ يَابْنَ اَميرِ الْمُؤْمِنيْنَ وَابْنَ سَيِّدِ الْوَصِيِّيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុត្ររបស់ព្រះអគ្គមហាប្រមុខរបស់បណ្តាអ្នកមានសទ្ធា និងព្រះអគ្គមហាប្រមុខរបស់បណ្តាអ្នកស្នង

اَلسَّلامُ عَلَيْكَ يَابْنَ فاطِمَةَ الزَّهْرَاءِ سَيِّدَةِ نِسَآءِ الْعَلَمِيْنَ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុត្ររបស់ហ្វាទីម៉ាស់ អាស់-ស្ហារ៉អ៍ ស្ត្រីឯកលើភពផែនដែនចក្រវាលទាំងពួង

اَلسَّلامُ عَلٰى الْحُسَيْنِ وَ عَلٰى عَلِيَّ بْنَ الْحُسَيْنِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱហ៊្សៃន៍ និងដល់អាលី បុត្ររបស់ហ៊្សៃន៍

وَ عَلٰى اَوْلَادِ الْحُسَيْنِ وَ عَلٰى اَصْحَابِ الْحُسَيْنِ

និងដល់បណ្តារាជបុត្ររបស់ហ៊្សៃន៍ និងដល់បណ្តាកនរបស់ហ៊្សៃន៍

جَمِيْعًا وَ رَحْمَةُ اللّٰهِ وَ بَرَكَاتُهُ

ទាំងអស់គ្នា ព្រមទាំងព្រះពរជ័យរបស់អល់ឡោះហ្វ៍ផងដែរ ។

## ស៊ីយ៉ារ៉ត្ថ អ៊ីម៉ាំ អាុលី អារ-រីដ្ហ៏ صلوات الله عليه والسلام

السَّلامُ عَلَيْكَ يَا مَوْلَايَ وَابْنَ مَوْلَايَ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះអគ្គមហាប្រមុខរបស់ទូលបង្គំ រាជបុត្ររបស់ព្រះអគ្គមហាប្រមុខរបស់ទូលបង្គំ

السَّلامُ عَلَيْكَ يَا غَرِيْبَ الْغُرَبَاء

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុរសបរទេសក្នុងចំណោមជនបរទេស

السَّلامُ عَلَيْكَ يَا سُلْطَانَ اَبَالْحَسَنِ عَلِيَّ بْنَ مُوْسَ الرِّضَا

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះអគ្គមគ្គទេសក៏របស់ទូលបង្គំ អាប៊ុលហ្ហាសាន់ អាុលី អារ-រីដ្ហ៏ រាជបុត្ររបស់មូសា

كُنْ شَفِيْعَنَا وَ شَفِيْعًا وَالِدَيْنَا فِيْ يَوْمِ الْجَزَاءِ

សូមព្រះអង្គជួយធ្វើអន្តរាគមន៍ឲ្យអស់ទូលបង្គំ និងឲ្យមាតាបិតាអស់ទូលបង្គំផង នាថ្ងៃជំនុំជម្រះ

وَرَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យពរជ័យនិងសិរីមង្គលរបស់អល់ឡោះហ្វ៍កើតមានដល់ព្រះអង្គ ។

## ស៊ីយ៉ារ៉ត្ថ អ៊ីម៉ាំ មូហ្ហាំម៉ាដ្ឋ អាល់-ម៉ាស្ទ្ឌី صلوات الله عليه والسلام

السَّلامُ عَلَيْكَ يَابْنَ الْحَسَنِ يَا صَاحِبَ الْعَصْرِ وَالزَّمَانِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱរាជបុត្ររបស់អាល់-ហ្ហាសាន់ ឱម្ចាស់សម័យកាលនិងម្ចាស់ពេលវេលា

السَّلامُ عَلَيْكَ يَا خَلِيْفَةَ الرَّحْمَانِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱបុគ្គលដែលព្រះដ៏មានព្រះមេត្តាធម៌បាន

ជ្រើសរើស (អល់ឡោះហ្វ)

السَّلامُ عَلَيْكَ يَا شَرِيْكَ الْقُرْآنِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱដៃគូរបស់គួរអាន

السَّلامُ عَلَيْكَ يَا كَعْبَةَ الْاِيْمَانِ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱកាក់បាស់នៃជំនឿ

السَّلامُ عَلَيْكَ يَا اِمَامَ الْاِنْسِ وَ الْجَنِّ

សូមឲ្យសិរីសួស្តីកើតមានដល់ព្រះអង្គ ឱអ៊ីម៉ាំរបស់មនុស្សនិងយ៉ិន

وَرَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមឲ្យពរជ័យនិងសិរីមង្គលរបស់អល់ឡោះហ្វកើតមានដល់ព្រះអង្គ ។

យើងគប្បីនឹកដល់អ៊ីម៉ាំទាំងអស់ﷺក្នុងស៊ុីយ៉ារ៉ត់ ។ ស៊ុីយ៉ារ៉ត់នេះវែងបន្តិច នឹងលើកយកមកបង្រៀនក្នុងមេរៀនក្រោយ ។

## កិច្ចការសិស្ស ១៣

តើតាក់គ្វីបាត់មានន័យថាអ្វី

_____________________________________________

_____________________________________________

ចូរផាត់ព័ណ៌លើរូបក៏លីប និងក៏លីបាស់កំពុងឈរសូត្រស៊ីយ៉ារ៉ត់



ស៊ីយ៉ារ៉ត់ដែលអ្នកបានរៀនមាន ៣ ប៉ែក ។ តើមានប៉ែកអ្វីខ្លះ (ឈ្មោះស៊ីយ៉ារ៉ត់) ?

_____________________________________________

_____________________________________________

_____________________________________________

ចូរទន្ទេញស៊ីយ៉ារ៉ត់ឲ្យចាំ ហើយព្យាយាមសូត្រស៊ីយ៉ារ៉ត់នោះក្នុងពេលស្វ័ឡាត់ ។

**មេរៀនទី ១៤**

# អ្វីដែលធ្វើឲ្យខូចវូឌ្ហុអ៊ុ

ទង្វើមួយចំនួនដែលធ្វើឲ្យវូឌ្ហុអ៊ុខូច (មោឃៈ) មាន ៖

១) បត់ជើងតូច បត់ជើងធំ

ប្រសិនបើក្រោយពីបានយកទឹកវូឌ្ហុអ៊ុហើយ អ្នកទៅបន្ទប់ទឹកដើម្បីបត់ជើងតូច ឬបត់ជើងធំ វូឌ្ហុអ៊ុរបស់អ្នកត្រូវខូច (បាទ្ទិល باطل) ហើយអ្នកចាំបាច់ត្រូវតែយកទឹកវូឌ្ហុអ៊ុសាថ្មី ។

២) ពេលដើរខ្យល់ (ផោម)

ប្រសិនបើក្រោយពីបានយកទឹកវូឌ្ហុអ៊ុហើយ អ្នកដើរខ្យល់ (ផោម) វូឌ្ហុអ៊ុរបស់អ្នកត្រូវខូច ។

៣) ដេកលក់

ប្រសិនបើក្រោយពីបានយកទឹកវូឌ្ហុអ៊ុហើយ អ្នកដេកលក់ វូឌ្ហុអ៊ុរបស់អ្នកត្រូវខូច ។ ឧទាហរណ៍ ប្រសិនបើអ្នកចូលដំណេកក្រោយពីបានយកទឹកវូឌ្ហុអ៊ុ តែវូឌ្ហុអ៊ុរបស់អ្នកត្រូវខូចចាប់ពីពេលដែលអ្នកដេកលក់មិនដឹងខ្លួន ។ អ្នកមិនអាចបំពេញស្វឡាត្ហ្វាជ់រ៍ បានទេ ដោយឥតយកទឹកវូឌ្ហុអ៊ុសាថ្មី ។

៤) បាត់ស្មារតី

ប្រសិនបើក្រោយពីបានយកទឹកវូឌ្ហុអ៊ុហើយ អ្នកបាត់បង់ស្មារតី (សន្លប់) វូឌ្ហុអ៊ុរបស់អ្នកត្រូវខូច ។

## កិច្ចការសិស្ស ១៤

ត្ត៏លិបកំពុងតែយកទឹកវូឌូអ៊ុំ តើត្ត៏លិបត្រូវចៀសវាងទង្វើណាដើម្បីកុំឲ្យខូចវូឌូអ៊ុំ ?

___

___

___

___

**មេរៀនទី ១៥**

# ទង្វើដែលបណ្តាលឲ្យខូចស្ទ័ឡាត់

ទង្វើមួយចំនួនដែលបណ្តាលឲ្យខូចស្ទ័ឡាត់ (ធ្វើឲ្យស្ទ័ឡាត់បាទិ្វល) មាន ៖

១- ទង្វើទាំងអស់ដែលធ្វើឲ្យខូចវូឌុអ៍ ។ ពោលគឺ បត់ជើងតូច បត់ជើងធំ ដើរខ្យល់ ដេកលក់ បាត់បង់ស្មារតី ។ល ។

២- បែរចេញពីគិ្លបឡាស់ (លើសពី ៤៥ ដឺក្រេ) ។ ប្រសិនបើបែរចេញពីគិ្លបឡាស់ ដោយចេតនា ឬដោយអចេតនា (ឧទាហរណ៍ ត្រូវខ្យល់បក់បោក) ស្ទ័ឡាត់ត្រូវខូច ។

៣- បរិភោគ និង ផឹក

៤- និយាយ ។ លើកលែងតែឆ្លើយតបសាឡាមដោយពាក្យថាសាឡាមដូចគ្នា (អាស់សាឡាមូ អ៊ុឡៃគុម)

៥- សើច (មិនមែនញញឹម)

៦- យំដោយសារអ្វីម្យ៉ាងដែលទាក់ទងនឹងជីវិតរស់នៅ

៧- គ្រប់ទង្វើដែលសន្មត់បានថាយើងមិនកំពុងតែបំពេញស្ទ័ឡាត់ទេ (ឧទាហរណ៍ ទេះដៃ លោត ។ល ។)

៨- ឱបដៃដោយចេតនា

៩- ថា "អាមីន" ពេលសូត្រស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ ចប់

១០- សង្ស័យនៅពេលបំពេញស្វ៌ឡាត់ពីរវ៉ក់អ្នុត្តំដំបូង (យើងនឹងអធិប្បាយពិស្តារក្នុងមេរៀនក្រោយ) ។

# កិច្ចការសិស្ស ១៥

ត្រ៉ូលីបកំពុងតែបំពេញស្រ្វឡាត្ត់ តើត្រ៉ូលីបមិនត្រូវធ្វើអ្វីខ្លះដើម្បីនឹងកុំឲ្យខូចស្រ្វឡាត្ត់ ?

______________________________________________

______________________________________________

______________________________________________

______________________________________________

**មេរៀនទី ១៦**

# ត៏ហ្វារ៉ោះត៏ និង ណាយ៉ាសាស់

ត៏ហ្វារ៉ោះត៏ (طهارة) មានន័យថា ភាពបរិសុទ្ធ (មិនមានន័យជាចាំបាច់ថាស្អាតទេ) ។

ណាយ៉ាសាស់ (نجاسة) មានន័យថា ភាពមិនបរិសុទ្ធ (មិនមានន័យជាចាំបាច់ថាកខ្វក់ទេ) ។

វត្ថុណាយ៉ិសនឹងធ្វើឲ្យវត្ថុឯទៀតណាយ៉ិសដែរ ប្រសិនបើវត្ថុទាំងនោះទទឹកហើយត្រូវវត្ថុណាយ៉ិសប៉ះពាល់ ។

អ្វីដែលអាចធ្វើឲ្យរបស់ដែលណាយ៉ិសទៅជាត៏ហ្វៀរបាន (គឺបរិសុទ្ធ) គេហៅថា មូតោ្ហះហ្ហីរ៉ោះត៏ (مطهرة) ។

វត្ថុមូតោ្ហះហ្ហីរ៉ោះត៏គឺ ៖

១-ទឹក
២-ថ្ងៃ
៣-ដី
៤-អ៊ីស្លាម

វត្ថុមួយចំនួនជា "អ៊ៃន៍ ណាយ៉ិស" ពោលគឺ ណាយ៉ីសស្រាប់តាំងពីដើមកំណើតរបស់វាមកម្ល៉េះ គឺ ៖

១-ទឹកនោម និង លាមក
២-ឈាម
៣-បុគ្គលស្លាប់ (សាកសព)

៤-កាហ្សៀរ

៥-ឆ្កែ

៦-ជ្រូក

៧-សុរា

# **កិច្ចការសិស្ស ១៦**

សត្វជ្រូកជា អ៉ែនី ណាឃ៉ិស ។ តើ អ៉ែនី ណាឃ៉ិស មានសេចក្តីថាអ្វី ?

ចូរសរសេរនៅលើរូបសត្វជ្រូក នូវឈ្មោះរបស់ អ៉ែន៍ ណាឃ៉ិស ឯទៀត ។



តើ ម្វតោះហ្វ៊ីរ៉ោះត្វ៍ មានសេចក្តីថាអ្វី ? ________________

ចូរឲ្យឈ្មោះវត្ថុ ម្វតោះហ្វ៊ីរ៉ោះត្វ៍ ។

តើ ត្វ៍ហ្វារ៉ោះត្វ៍ និង ណាយ៉ោសាស្វ៍ ខុសគ្នាត្រង់ណា ?

តើវត្ថុណាឃ្វិសអាចធ្វើឲ្យវត្ថុផ្សេងទៀតទៅជាណាឃ្វិសបានដូចម្ដេច ?

________________________________________________

_______________________________________

**មេរៀនទី ១៧**

# ស៊ោម៍

ស៊ោម៍ (صوم) មានន័យថា តមអាហារ ។ ចៀសវាងធ្វើអំពើដែលបណ្ដាលឲ្យការកាន់ត្រណមដាច់ ឬ ខូច ចាប់ពីពេលមុនថ្ងៃរះពិតប្រាកដ (ស៊ុបហ៊ ស៊ូឌិក្ទ) រហូតដល់ពេលម៉ាក់រីប (ថ្ងៃលិច) ។

វ៉ាយិបត្រូវកាន់ត្រណមអាហារមួយខែរ៉ម៉ាដូន ។

ខែរ៉ម៉ាដូនជាខែពិសិដ្ឋបំផុតក្នុងប្រក្រតិទិនអ៊ីស្លាម ។

មគ្គផលដែលមានក្នុងខែនេះគឺ ៖
១-ព្រះមហាគម្ពីរគួរអាន
២-យប់ អាល់-ក្វដ៏រ៍ (ليلة القدر)

ពេញមួយខែនេះ ទង្វើនីមួយៗ ល្អឬអាក្រក់ នឹងធ្ងន់ជាងសព្វដង ។ ដូច្នេះ សូត្រគួរអានជាទង្វើប្រសើរគ្រប់ពេល តែវាប្រសើរលើសនោះទៅទៀតក្នុងខែរ៉ម៉ាដូន ។ និយាយកុហកជាទង្វើអាក្រក់មួយ តែវាជាអំពើអាក្រក់លើសនោះទៅទៀតក្នុងខែរ៉ម៉ាដូន ។

ស៊ោម៍ មិនមានន័យថាស៊ូអត់បាយនិងអត់ទឹកពេលថ្ងៃនោះទេ គឺមានន័យថាហាមខ្លួនឯងប្រព្រឹត្តគ្រប់អំពើដែលត្រូវហាមព្រមនឹងអត់អាហារ ។

ស៊ោម៍ អាចធ្វើឲ្យអ្នក ៖
១-មានឆន្ទៈកាន់តែមាំឡើង
២-គិតថាអ្នកដទៃមិនមានសំណាងស្មើខ្លួនអ្នកទេ
៣-នឹកដល់អស់ឡោះហ្វ៍ញឹកញយក្នុងពេលថ្ងៃ

៤-លាងសម្អាតពោះរបស់អ្នក

៥-ផ្លាស់ប្តូររបៀបរស់នៅរបស់អ្នកឲ្យដូចមុស្លីមពិតប្រាកដ ។

## កិច្ចការសិស្ស ១៧

តើស្មៅម៍នាំមកឲ្យអ្នកនូវអត្ថប្រយោជន៍អ្វីខ្លះ ?

______________________________
______________________________
______________________________
______________________________
______________________________

តើស្មៅម៍មានន័យថាអ្វី ? តើស៊ូទ្រាំអត់អាហារតែមួយមុខឬទេ ?

______________________________________________
______________________________

តើគេកាន់ត្រណមស្មៅម៍ពីពេលណាដល់ពេលណា ?

______________________________________________

តើនៅក្នុងខែណាដែលការកាន់ត្រណមស្មៅម៍នោះជាវ៉ាឃ្ជិប ?

______________________________________________

តើមគ្គផលធំជាងគេក្នុងខែនេះគឺអ្វី ?

______________________________________________

**មេរៀនទី ១៨**

# ហ៊ីយ៉ាប់ (សម្រាប់នារី)

នារីប្រើហ៊ីយ៉ាប់ដើម្បី ៖

១- ចៀសវាងស្ថានភាពដែលមានជន ណា-ម៉ាស៊ូរ៉ម (គឺមិនមែនម៉ាស៊ូរ៉ម) (នៅពេលជួបជុំគ្នា)

២- បើមានជន ណា-ម៉ាស៊ូរ៉ម នៅជាមួយ មិនត្រូវមើលជននោះដោយមិនចាំបាច់ទេ ហើយមិនត្រូវទាក់ទាញអារម្មណ៍គេមកលើខ្លួនទេ (ដោយនិយាយ ឬ សើចខ្លាំងជាដើម)

៣- គ្របខ្លួន និង សក់

ជន ណា-ម៉ាស៊ូរ៉ម ជាអ្នកណា ៖

បុរសទូទៅជាជន ណា-ម៉ាស៊ូរ៉ម លើកលែងតែ ៖

-ឪពុកអ្នក និង ជីតាអ្នក

-បងប្រុសនិងប្អូនប្រុសអ្នកនិងកូនៗ (និងកូនៗរបស់បងប្អូនស្រីអ្នក)

-បងប្អូនប្រុសរបស់ឪពុកអ្នក (ឪពុកមា ឪពុកធំ ខាងឪពុក)

-បងប្អូនប្រុសរបស់ម្តាយអ្នក (ឪពុកមា ឪពុកធំ ខាងម្តាយ)

-ស្វាមីអ្នក កូនៗរបស់គាត់និងឪពុកគាត់

-កូនៗរបស់អ្នក (បើអ្នកជាយាយ ចៅៗរបស់អ្នកផងដែរ)

ពាក់ហ៊ីយ៉ាប់ជាវ៉ាយិបសម្រាប់ស្ត្រីគ្រប់រូប ចាប់ពីអាយុ ៩ ឆ្នាំឡើងទៅ ។

ហ៊ីយ៉ាប់មិនមានន័យថាបិទបាំងតែសក់ទេ តែបិបាំងដងខ្លួនអ្នកផងដែរ ។ បានសេចក្តីថា មិនអនុញ្ញាតឲ្យបង្ហាញទ្រង់ទ្រាយខ្លួនរបស់អ្នកទេ (ទ្រង់ទ្រាយស្តម ឬ ធាត់) ។

សាសនាអ៊ីស្លាមឲ្យយើងបិទបាំងខ្លួន ពីព្រោះក្នុងសាសនាអ៊ីស្លាម គេទុកស្ត្រីជាទ្រព្យសម្បត្តិដែលល្អ ។

យើងទុកទ្រព្យសម្បត្តិដែលមានតម្លៃរបស់យើង នៅឯកន្លែងដែលមានសុវត្ថិភាពនិងបិទបាំងដើម្បីការពារការឆក់លួច ។ ដូច្នេះហើយបានជាត្រូវការពារសម្រស់ស្ត្រី ។

# កិច្ចការសិស្ស ១៨

តើស្ត្រីប្រើហ្មុីយ៉្ហាប់ដើម្បីអ្វី ?

______________________________

______________________________

______________________________

តើអ្នកណាជាជនម៉ាស៊ូរ៉មែសម្រាប់អ្នក ?

______________________________

______________________________

______________________________

ចូរគូររូបសំលៀកបំពាក់ដែលគួរឲ្យពេញចិត្ត និងដែលដូចហ្មុីយ៉្ហាប់ ។

កំណែលើកទី ២, 06/2020